Washington State's
Child Support Program



English-language Learner

# Glossary

## English to **Cambodian**

DSHS, Division of Child Support (DCS)
definitions for translation into Cambodian

Washington State
Department of Social
& Health Services
*Transforming lives*

English-language Learner

# Glossary

## English to **Cambodian**

DSHS, Division of Child Support (DCS)
definitions for translation into Cambodian

## Preface

This document is designed to help reviewers, interpreters and translators working on Division of Child Support (DCS) brochures. The definitions are a mixture of common knowledge, child support terms, legal terms and dictionary usage.

The intent is to update the glossary periodically and to provide versions in: Cambodian, Chinese, Korean, Laotian, Russian, Somali, Spanish and Vietnamese.

Please send additions and corrections to:


Washington State Department of Social and Health Services
DCS Communications Operations
English-language Learner Glossary
PO Box 9162
MS: 45860
Olympia, WA  98507-9162

Call:  1-800-457-6202

E-mail:  DCS-CRU@dshs.wa.gov



Washington State
Department of Social
& Health Services
Transforming lives

# Acknowledgement

The Division of Child Support (DCS) wishes to express its sincere gratitude to those individuals who offered their expertise and devoted time and energy in creating and reviewing the translation of this glossary. The project would not have been possible without their support and help.

Parts of Speech Abbreviations

| | |
|---|---|
| *adv.* | adverb |
| *adj.* | adjective |
| *n.* | noun |
| *prep.* | preposition |
| *v.* | verb |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Absent Parent** *n.* | AP | ឪពុក/ម្តាយដែលអវត្តមាន | Absent Parent (AP) -The parent who does not live in the home with the child and has a responsibility to pay support. APs are also referred to as nonresidential parents, noncustodial parents and responsible parents. **Cambodian –** ឪពុក/ម្តាយដែលអវត្តមាន **(AP) -** ឪពុក/ម្តាយដែលមិនរស់នៅក្នុងផ្ទះជាមួយកូន និងមានទំនួលខុសត្រូវក្នុងការទូទាត់ប្រាក់ឧបត្ថម្ភ។ **APs** ក៏សំដៅដល់ឪពុកម្តាយដែលមិនមែនជានិវាសនជន ឪពុកម្តាយដែលគ្មានសិទ្ធិចិញ្ចឹមបីបាច់ និងឪពុកម្តាយ ដែលមានទំនួលខុសត្រូវ។ |
| **Account** *n.* | ACCT | គណនី | Account Number - The number used in automated case processing to identify the individual making a payment. Synonymous with BI number. **Cambodian –** លេខគណនី - លេខដែលត្រូវបានប្រើប្រាស់នៅក្នុងការដំណើរការរឿងក្តីដោយស្វ័យប្រវត្តិ ដើម្បីសម្គាល់បុគ្គលដែលធ្វើការទូទាត់ប្រាក់។ មានន័យស្មើនឹងលេខ **BI**។ |
| **Acknowledge** *n.* | ACK | ទទួលស្គាល់ | To recognize, report the receipt of, or to accept or certify as legally binding. **Cambodian –** ដើម្បីទទួលស្គាល់ រាយការណ៍អំពីការទទួលបាន ឬការទទួលយក ឬការបញ្ជាក់ ថាបានចងកាតព្វកិច្ចស្របច្បាប់។ |
| **Additional** *adj.* | ADDL | បន្ថែម | Adding more information to a text or numbers when finding a sum. **Cambodian –** បន្ថែមព័ត៌មានបន្ថែមទៅក្នុងអត្ថបទ ឬលេខនៅពេលស្វែងរកចំនួនសរុប។ |
| **Address Confidentiality Program** *n.* | ACP | កម្មវិធីរក្សាការសម្ងាត់អាសយដ្ឋាន | A Washington state program that allows victims of domestic violence to hide their addresses when dealing with state and local government agencies. The Secretary of State's Office is responsible for the program and acts as an agent for service of process. **Cambodian –** កម្មវិធីរបស់រដ្ឋវ៉ាស៊ីនតោនដែលអនុញ្ញាតឲ្យជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារបិតបាំងអាសយដ្ឋានរបស់ពួកគេនៅពេលដោះស្រាយជាមួយទីភ្នាក់ងាររដ្ឋ និងទីភ្នាក់ងាររដ្ឋាភិបាលក្នុងមូលដ្ឋាន។ លេខាធិការរបស់ការិយាល័យរដ្ឋទទួលខុសត្រូវចំពោះកម្មវិធី និងដើរតួជាភ្នាក់ងារសម្រាប់សេវានៃដំណើរការ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Adjust**<br>*v.*<br>**Adjustment**<br>*n.* | ADJ | កែសម្រួល<br>ការកែសម្រួល | To change to match or fit as to new conditions or regulations. To change the amount to be paid or the amount owed on a debt. **Cambodian –** ផ្លាស់ប្តូរដើម្បីធ្វើឲស៊ីគ្នា ឬឲស័ក្តិសមទៅនឹងលក្ខខណ្ឌ និងបទប្បញ្ញត្តិថ្មី។ ផ្លាស់ប្តូរ ចំនួនទឹកប្រាក់ដែលត្រូវទូទាត់ ឬចំនួនដែលជំពាក់នៅលើបំណុល។ |
| **Administration for Children and Families**<br>*n.* | ACF | រដ្ឋបាលសម្រាប់កុមារ<br>និងក្រុមគ្រួសារ | The federal umbrella agency that contains OCSE (Office of Child Support Enforcement). **Cambodian –** ទីភ្នាក់ងារកណ្តាលសហព័ន្ធដែលមាន **OCSE** (ការិយាល័យអនុវត្តប្រាក់អាហារូត្ថម្ភ)។ |
| **Administrative Debt**<br>*n.* | | បំណុលរដ្ឋបាល | The support arrears established and accruing under an administrative order, an Agreed Settlement, Consent Order, Decision and Order, or default Notice and Finding of Parental Responsibility. **Cambodian –** ការទូទាត់ប្រាក់ឧបត្ថម្ភត្រូវបានបង្កើតឡើង និងបង្គរយោងតាមដីកាផ្នែករដ្ឋបាល ការដោះស្រាយដែលបានព្រមព្រៀងគ្នា ដីកាដោយមានការយល់ព្រម សេចក្តីសម្រេច និងដីកា ឬសេចក្តីជូនដំណឹងអំពីការមិនបានបំពេញកាតព្វកិច្ច និងលទ្ធផលនៃទំនួលខុសត្រូវរបស់ឪពុកម្តាយ។ |
| **Administrative Hearings (Adjudicative proceedings)**<br>*n.* | AH | សវនាការរដ្ឋបាល (ដំណើរការរឿងក្តីបែបវិនិច្ឆ័យ) | An adjudicative proceeding under the Administrative Act (Chapter 34.05 RCW). The law requires that hearings be recorded and allows the parties to petition for review of hearing decisions. An administrative hearing is a formal process by which an Administrative Law Judge decides contested issues. Also known as adjudicative hearing and adjudicative proceeding. **Cambodian –** ដំណើរការរឿងក្តីបែបវិនិច្ឆ័យយោងតាមច្បាប់រដ្ឋបាល (ជំពូក **34.05 RCW**)។ ច្បាប់តម្រូវថាសវនាការត្រូវបានកត់ត្រាទុក និងអនុញ្ញាតឲគូភាគីនៃបណ្តឹងធ្វើការ ត្រួតពិនិត្យសេចក្តីសម្រេចរបស់សវនាការឡើងវិញបាន។ សវនាការរដ្ឋបាលគឺជា ដំណើរការផ្លូវការដែលចៅក្រមនៃច្បាប់រដ្ឋបាលធ្វើការសម្រេចចំពោះបញ្ហាដែលមានជម្លោះ។ ត្រូវបានស្គាល់ផងដែរថាជាសវនាការបែបវិនិច្ឆ័យ និងដំណើរការរឿងក្តីបែបវិនិច្ឆ័យ។ |
| **Administrative Law Judge**<br>*n.* | ALJ | តុលាការច្បាប់រដ្ឋបាល | Administrative issues. As the presiding officer in an adjudicative proceeding, the Administrative Law Judge conducts the hearing and enters the initial decision and order. **Cambodian –** បញ្ហារដ្ឋបាល។ ក្នុងនាមជាមន្ត្រីដឹកនាំនៅក្នុងដំណើរការរឿងក្តីបែបវិនិច្ឆ័យចៅក្រម នៃច្បាប់រដ្ឋបាលបើកសវនាការ និងធ្វើការសម្រេច និងដីកាដំបូង។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Administrative Order**<br>*n.* | AO | ដីកាផ្ដែករដ្ឋបាល | Established in a non-judicial system. An administrative order can be established by agreement with Support Enforcement Officer (SEO), or in a hearing held before an ALJ, or by default on an administrative notice or hearing. DCS establishes an administrative order for payment of child support. **Cambodian –** ដោយមិនត្រូវបានបង្កើតឡើងនៅក្នុងប្រព័ន្ធតុលាការ។ ដីកាផ្ដែករដ្ឋបាលអាច ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងជាមួយមន្រ្តីអនុវត្តប្រាក់ឧបត្ថម្ភ **(SEO)** ឬនៅក្នុងសវនាការមួយដែលត្រូវបានធ្វើឡើងនៅចំពោះមុខ **ALJ** ឬដោយការកំណត់ជាមុននៅលើសេចក្ដីជូនដំណឹងផ្ដែករដ្ឋបាល ឬសវនាការ។ **DCS** បង្កើតដីកាផ្ដែករដ្ឋបាលសម្រាប់ការទូទាត់ប្រាក់អាហារូបត្ថម្ភ។ |
| **Administrative Process**<br>*n.* | ADMIN | ដំណើរការផ្ដែករដ្ឋបាល | Procedures that allow a state agency to administer a program without court action SEO uses the administrative process to establish and enforce a support order without court action. **Cambodian –** នីតិវិធីដែលអនុញ្ញាតឲទីភ្នាក់ងាររដ្ឋធ្វើការគ្រប់គ្រងកម្មវិធីដោយពុំមានចំណាត់ការរបស់តុលាការ **SEO** ប្រើប្រាស់ដំណើរការរដ្ឋបាលដើម្បីបង្កើត និងអនុវត្តដីកាប្រាក់ឧបត្ថម្ភដោយពុំចាំបាច់មានចំណាត់ការរបស់តុលាការ។ |
| **Affidavit**<br>*n.* | AFF | សេចក្ដីថ្លែងសច្ចា | A written statement made under oath before a notary public or other person authorized to administer oaths. **Cambodian –** សេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរមួយច្បាប់ត្រូវបានធ្វើឡើងយោងតាមការ ស្បថស្បែរនៅចំពោះមុខសារការីសាធារណ: ឬបុគ្គលដទៃទៀតដែលទទួលបានការអនុញ្ញាតឲគ្រប់គ្រងការស្បថស្បែរ។ |
| **Agreed Settlement**<br>*n.* | | ការដោះស្រាយដោយមានការព្រមព្រៀង | A written negotiated agreement establishing current support and arrears or the amount due under a prior support order. An Agreed Settlement is an administrative order that does not require the signature of an ALJ. **Cambodian –** កិច្ចព្រមព្រៀងដែលបានចរចាគ្នាជាលាយលក្ខណ៍អក្សរមួយច្បាប់បង្កើតប្រាក់ឧបត្ថម្ភ បច្ចុប្បន្ន និងប្រាក់ទូទាត់តាមក្រោយ ឬប្រាក់ដែលដល់កំណត់បង់យោងតាមដីកាប្រាក់ឧបត្ថម្ភជាមុន។ ការដោះស្រាយដែលបានព្រមព្រៀង គឺជាដីកាផ្ដែករដ្ឋបាលដែលមិនត្រូវការហត្ថលេខារបស់ **ALJ**។ |
| **Aid to Families with Dependent Children - Foster Care**<br>*n.* | AFDC-FC | ជំនួយដល់ក្រុមគ្រួសារដែលមានកូនក្នុងបន្ទុក-ការចិញ្ចឹមថែទាំ | A foster care program funded by the TANF-FC. See Temporary Assistance for Needy Families. Children must be categorically needy according to the federal definition. **Cambodian –** កម្មវិធីចិញ្ចឹមថែទាំ ទទួលបានមូលនិធិពី **TANF-FC**។ ចូរមើលជំនួយបណ្ដោះអាសន្នសម្រាប់ក្រុមគ្រួសារដែលមានការខ្វះខាត។ កុមារត្រូវតែបានចាត់ថ្នាក់ថា មានការខ្វះខាតយោងតាមនិយមន័យរបស់សហព័ន្ធ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Alleged Father** *n.* | AF | ឪពុកដែលត្រូវបានចោទប្រកាន់ | Father represented as existing or as being as described but not so proved; supposed father. **Cambodian –** ឪពុកត្រូវបានតំណាងថាមានវត្តមាន ឬដូចបានពិពណ៌នា ប៉ុន្តែមិនត្រូវបញ្ជាក់អះអាងថាមានវត្តមាន ជាឪពុកដែលត្រូវបានសន្មត។ |
| **Algorithm** *n.* | | ប្រព័ន្ធសំខ្យាអារ៉ាប់ | The mathematical formula by which DCS distributes payments to current and arrears. The algorithm applies money first to current support. It distributes the payment proportionately if the NCP (non-custodial parent) has multiple current obligations and the payments are not large enough to pay current support on all NCP's cases. Next, the algorithm distributes proportionately between all arrears in all cases associated with the payer. It distributes to CP (custodial parent) arrears within each case before any subrogated debt within that same case. **Cambodian –** រូបមន្តគណិតវិទ្យាដែល **DCS** បែងចែកការទូទាត់ប្រាក់បច្ចុប្បន្ន និងប្រាក់ទូទាត់តាមក្រោយ។ ប្រព័ន្ធសំខ្យាអារ៉ាប់ **(algorithm)** ផ្តល់ប្រាក់ដល់ការឧបត្ថម្ភនាពេលបច្ចុប្បន្នជាមុន។ ប្រព័ន្ធនេះបែងចែកប្រាក់តាមសមាមាត្រ ប្រសិនបើ **NCP** (ឪពុក/ ម្តាយដែលពុំមានសិទ្ធិចិញ្ចឹមបីបាច់) មានកាតព្វកិច្ចបច្ចុប្បន្នច្រើន ហើយមានប្រាក់មិន ច្រើនគ្រប់គ្រាន់សម្រាប់ធ្វើការទូទាត់ប្រាក់ឧបត្ថម្ភនាពេលបច្ចុប្បន្ននៅគ្រប់រឿងក្តី របស់ **NCP**។ បន្ទាប់មក ប្រព័ន្ធសំខ្យាអារ៉ាប់ **(algorithm)** បែងចែកតាម សមាមាត្ររវាងប្រាក់ទូទាត់តាមក្រោយទាំងអស់នៅគ្រប់រឿងក្តីទាំងអស់ដែល ពាក់ព័ន្ធនឹងអ្នកទូទាត់ប្រាក់។ ប្រព័ន្ធនេះបែងចែកប្រាក់ទៅកាន់ **CP** (ឪពុក/ម្តាយ ដែលមានសិទ្ធិចិញ្ចឹមបីបាច់) តាមក្រោយ នៅក្នុងរឿងក្តីនីមួយៗមុនបំណុលជំនួសណាមួយនៅក្នុងរឿងក្តីដូចគ្នានោះ។ |
| **Also Known As** *adv.phrase* | AKA | ត្រូវបានស្គាល់ផងដែរថាជា | Known by different names. **Cambodian –** ត្រូវបានស្គាល់ដោយឈ្មោះខុសៗគ្នា។ |
| **Alternate Arrangement** *n.* | | ការចាត់ចែងជំនួស | A court order approving an alternate arrangement that authorizes the nonresidential parent to make payments directly to the physical custodian or another party. **Cambodian –** ដីកាតុលាការដែលឯកភាពចំពោះការចាត់ចែងជំនួសណាមួយដែលអនុញ្ញាតឲ ឪពុក/ម្តាយដែលមិនមែនជានិវាសនជនធ្វើការទូទាត់ប្រាក់ទៅកាន់អ្នកមានសិទ្ធិចិញ្ចឹមបីបាច់ផ្នែករូបវន្ត ឬភាគីណាមួយផ្សេងទៀតដោយផ្ទាល់។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Alternate Payment Plan**<br>*n.* | | ផែនការទូទាត់ប្រាក់ជំនួស | A court order that authorizes the nonresidential parent to make payments directly to the physical custodian or another party. In 1994 the Alternate Payment Plan was removed from Washington state law but the new legislation provided for "alternate arrangements"(see above).<br>**Cambodian –** ដីកាតុលាការដែលអនុញ្ញាតឲឪពុក/ម្ដាយដែលមិនមែនជានិវាសនជនធ្វើការទូទាត់ ប្រាក់ទៅកាន់អ្នកមានសិទ្ធិចិញ្ចឹមបីបាច់ផ្នែករូបវន្ត ឬភាគីណាមួយផ្សេងទៀតដោយផ្ទាល់។ នៅក្នុងឆ្នាំ **1994** ផែនការទូទាត់ប្រាក់ជំនួសត្រូវបានលុបចេញពីច្បាប់របស់រដ្ឋវ៉ាស៊ីនតោន ប៉ុន្តែនីតិកម្មថ្មីបានចែងអំពី **"**ការចាត់ចែងជំនួស**"** (ចូរមើលខាងលើ)។ |
| **Annualizing Payments**<br>*adv. phrase* | | ការទូទាត់ប្រាក់ប្រចាំឆ្នាំ | Multiplying the monthly payment obligation by 12, and then dividing by the number of pay periods in a year.<br>**Cambodian –** គុណកាតព្វកិច្ចក្នុងការទូទាត់ប្រាក់នឹង **12** បន្ទាប់មកចែកនឹងចំនួនថិរវេលាក្នុងការទូទាត់ប្រាក់ក្នុងមួយឆ្នាំ។ |
| **Applicant Custodian, non-assistance custodian**<br>*n.* | AC | អ្នកមានសិទ្ធិចិញ្ចឹមបីបាច់ដែលដាក់ពាក្យស្នើសុំ, អ្នកមានសិទ្ធិចិញ្ចឹមបីបាច់ដែលគ្មានជំនួយ | The person who lives in the home with the child and receives either full collection or Payment Services Only (PSO) services from DCS. ACs is also referred to as physical custodians, residential parents, and custodial parents. A medical assistance only (MAO) recipient is also an AC. See Custodial Parent. **Cambodian –**<br>បុគ្គលដែលរស់នៅជាមួយកូន និងទទួលបានសេវាប្រមូលប្រាក់គ្រប់ចំនួន ឬសេវាទូទាត់ប្រាក់តែមួយមុខគត់ **(PSO)** ពី **DCS**។ **ACs** ក៏សំដៅដល់អ្នកមានសិទ្ធិចិញ្ចឹមបីបាច់ផ្នែករូបវន្ត ឪពុកម្ដាយដែលជានិវាសនជន និងឪពុកម្ដាយដែលមានសិទ្ធិចិញ្ចឹមបីបាច់។ អ្នកទទួលជំនួយផ្នែកវេជ្ជសាស្ត្រតែមួយមុខគត់ **(MAO)** ក៏ជា **AC** ផងដែរ។ ចូរមើល ឪពុកម្ដាយដែលមានសិទ្ធិចិញ្ចឹមបីបាច់។ |
| **Application**<br>*n.* | APP | ពាក្យស្នើសុំ | Any one of the following: a written and signed request for IV-D services; receipt of public assistance payments or medical assistance only (statutory application); receipt by Washington State Child Support Registry (WSSR) of an order from January 1, 1988, through August 31, 1991.<br>**Cambodian –** ចំណុចណាមួយក្នុងចំណោមចំណុចនានាដូចតទៅនេះ៖ សំណើជាលាយលក្ខណ៍អក្សរ និងបានចុះហត្ថលេខាសម្រាប់សេវា **IV-D,** បង្កាន់ដៃទូទាត់ប្រាក់សម្រាប់ ជំនួយសាធារណៈ ឬជំនួយផ្នែកវេជ្ជសាស្ត្រតែមួយមុខគត់ (ពាក្យស្នើសុំតាមផ្លូវ ច្បាប់), បង្កាន់ដៃទូទាត់ប្រាក់ដោយការិយាល័យចុះបញ្ជីប្រាក់អាហារូបត្ថម្ភនៃរដ្ឋ វ៉ាស៊ីនតោន **(WSSR)** តាមដីកាណាមួយចាប់ពីថ្ងៃទី **1** ខែមករា ឆ្នាំ **1988** រហូតដល់ថ្ងៃទី **31** ខែមករា ឆ្នាំ **1991**។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Arrears** *pl.,* **Arrearages** *n.* | ARRS | ការទូទាត់ប្រាក់តាមក្រោយ | Support debt; past due support or a judgment amount as stated in a court order or administrative order. **Cambodian –** បំណុលប្រាក់ឧបត្ថម្ភ, ប្រាក់ឧបត្ថម្ភដែលដល់កំណត់បង់លើកមុនឬចំនួនទឹកប្រាក់នៃ សាលក្រម ដែលមានចែងនៅក្នុងដីកាតុលាការ ឬដីកាផ្នែករដ្ឋបាល។ |
| **Arrears - DSHS** *n.* | | ការទូទាត់ប្រាក់តាមក្រោយ - DSHS | Also known as Permanently Assigned Arrears: 1) The arrears which accrued under an assignment of support rights in effect prior to Oct. 1, 1997, which do not exceed the cumulative amount of unreimbursed assistance paid to the family. 2) All arrears which accrue while a family is receiving assistance without regard to date, which do not exceed the cumulative amount of unreimbursed assistance paid to the family. **Cambodian –** ត្រូវបានស្គាល់ផងដែរថាជាប្រាក់ទូទាត់តាមក្រោយដែលត្រូវបានកំណត់ជាអចិន្ត្រៃយ៍ : **1)** ប្រាក់ទូទាត់តាមក្រោយដែលបានបង្គរយោងតាមការកំណត់សិទ្ធិទូទាត់ប្រាក់ ឧបត្ថម្ភដែលចូលជាធរមានមុនថ្ងៃទី **1** ខែតុលា ឆ្នាំ **1997** ដែលមិនលើសពីចំនួន បូកបញ្ចូលគ្នានៃជំនួយដែលមិនបង្វិលសងវិញដែលត្រូវបានទូទាត់ជូនគ្រួសារនោះ។ **2)** ប្រាក់ទូទាត់តាមក្រោយទាំងអស់ដែលបង្គរខណៈពេលដែលគ្រួសារមួយកំពុងទទួលបានជំនួយដោយមិនគិតពីកាលបរិច្ឆេទ ដែលមិនលើសពីចំនួនបូកបញ្ចូលគ្នា នៃជំនួយដែលមិនបង្វិលសងវិញដែលត្រូវបានទូទាត់ជូនគ្រួសារនោះ។ |
| **Arrears-Assigned Temporarily** *n.* | | ការទូទាត់ប្រាក់តាមក្រោយ-ការទូទាត់ប្រាក់បណ្ដោះអាសន្នដែលបានចាត់តាំង | Those arrears which accrued prior to the family receiving assistance and which were assigned to the state on or after Oct. 1, 1997. These arrears are not permanently assigned but are temporarily assigned to the state until Oct. 1, 2000, or the date the family leaves the assistance program, whichever date is later. **Cambodian –** ប្រាក់ទូទាត់តាមក្រោយដែលបានបង្គរមុនពេលដែលគ្រួសារនោះទទួលបានជំនួយ និងដែលត្រូវបានកំណត់ចំពោះរដ្ឋនៅ ឬនៅក្រោយថ្ងៃទី **1** ខែតុលា ឆ្នាំ **1997**។ ប្រាក់ទូទាត់តាមក្រោយទាំងនេះមិនត្រូវបានកំណត់ជាអចិន្ត្រៃយ៍នោះទេ ប៉ុន្តែត្រូវបានកំណត់ជាបណ្ដោះអាសន្នចំពោះរដ្ឋរហូតដល់ ថ្ងៃទី **1** ខែតុលា ឆ្នាំ **2000** ឬ កាលបរិច្ឆេទដែលគ្រួសារនោះចាកចេញពីកម្មវិធីជំនួយ កាលបរិច្ឆេទដែលកើតឡើងក្រោយគេ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Arrears-Non Assistance** *n.* | | ការទូទាត់ប្រាក់តាមក្រោយ-ពុំមានជំនួយ | 1) All arrears that accrue in non-assistance cases. 2) Arrears that accrue after the family's most recent period of assistance ends. **Cambodian – 1)** ប្រាក់ទូទាត់តាមក្រោយទាំងអស់ដែលបង្ករនៅក្នុងរឿងក្តីដែលមិនមែនជាជំនួយ។ **2)** ប្រាក់ទូទាត់តាមក្រោយដែលបង្ករក្រោយពេលបញ្ចប់រយៈពេលទទួលជំនួយថ្មីៗ បំផុតរបស់គ្រួសារនោះ។ |
| **Arrears Permanently Assigned** *n.* | | ការទូទាត់ប្រាក់តាមក្រោយជាអចិន្ត្រៃយ៍ដែលបានចាត់តាំង | Refers to public assistance money given to a custodial parent during a time when the noncustodial parent did not make payments. If at some future date the custodial parent reapplies for public assistance she or he must sign a waiver assigning the unpaid child support. **Cambodian –** សំដៅដល់ទឹកប្រាក់ជំនួយសាធារណៈដែលត្រូវបានប្រគល់ជូនឪពុក/ម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ក្នុងអំឡុងរយៈពេលមួយដែលឪពុក/ម្តាយដែលមិនពុំមានសិទ្ធិចិញ្ចឹមបីបាច់មិនបានធ្វើការទូទាត់ប្រាក់។ ប្រសិនបើនៅកាលបរិច្ឆេទមួយចំនួននាពេលអនាគត ឪពុក/ម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ដាក់ពាក្យស្នើសុំជំនួយសាធារណៈ នាង ឬគាត់ត្រូវតែចុះហត្ថលេខាលើការលះបង់សិទ្ធិចំពោះការកំណត់ប្រាក់អាហារូបត្ថម្ភដែលមិនទាន់បានទូទាត់។ |
| **Assets** *n.* | | ទ្រព្យសកម្ម | All sources of income as well as all personal and real property owned by an individual. **Cambodian –** រាល់ប្រភពចំណូលទាំងអស់ព្រមទាំងទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងអចលនទ្រព្យដែលកាន់កាប់ដោយបុគ្គលណាម្នាក់។ |
| **Assignments** *n.* | | ការចាត់តាំង | When the custodial parent gives DSHS all rights to support owed for the children who receive public assistance in order to offset the public assistance. Receipt of public assistance benefits, such as AFDC, foster care and Family Independence Program (FIP) is an assignment by operation of law. A recipient of medical assistance only (Medicaid) assigns all rights to medical support by operation of law. **Cambodian –** នៅពេលដែលឪពុក/ម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ប្រគល់ជូន **DSHS** នូវរាល់សិទ្ធិ ទាំងអស់ចំពោះប្រាក់ឧបត្ថម្ភដែលនៅជំពាក់សម្រាប់កូនៗដែលទទួលបានជំនួយ សាធារណៈដើម្បីកាត់កងជាមួយជំនួយសាធារណៈនោះ។ ការទទួលបានផល ប្រយោជន៍នៃជំនួយសាធារណៈ ដូចជា **AFDC**, ការចិញ្ចឹមថែទាំ និងកម្មវិធី ភាពឯករាជ្យរបស់គ្រួសារ **(FIP)** គឺជាការចាត់តាំងដោយប្រតិបត្តិការនៃច្បាប់។ អ្នកទទួលបានជំនួយផ្នែកវេជ្ជសាស្ត្រតែមួយមុខគត់ **(Medicaid)** ធ្វើការកំណត់ សិទ្ធិក្នុងការទទួលបានប្រាក់ឧបត្ថម្ភផ្នែកវេជ្ជសាស្ត្រដោយប្រតិបត្តិការនៃច្បាប់។ |

## Division of Child Support

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Assistant Attorney General**<br>*n.* | AAG | ជំនួយការអគ្គមេធាវី | An attorney in the Attorney General's Office. **Cambodian –** មេធាវីណាម្នាក់នៅក្នុងការិយាល័យអគ្គមេធាវី។ |
| **Associations**<br>*n.* | ASSN | សមាគម | An organized group of people who share a common interest, activity or purpose. **Cambodian –** ក្រុមមនុស្សដែលត្រូវបានរៀបចំឡើងដែលមានចំណាប់អារម្មណ៍ សកម្មភាព ឬគោលបំណងដូចគ្នា។ |
| **At**<br>*prep.* | @ | នៅ | A symbol used in internet addresses to indicate where the electronic mail (email) is sent. **Cambodian –** សញ្ញាសម្គាល់ដែលត្រូវបានប្រើប្រាស់នៅក្នុងអាសយដ្ឋានអ៊ីនធឺណិតដើម្បីចង្អុល បង្ហាញអំពីទីកន្លែងដែលសារអេឡិចត្រូនិចត្រូវបានផ្ញើចេញ។ |
| **Attachments**<br>*n.* | ATT | ឯកសារភ្ជាប់ | 1) Adding a form or other information to a letter or email. **Cambodian – 1)** បន្ថែមទម្រង់ណាមួយ ឬព័ត៌មានផ្សេងទៀតទៅក្នុងលិខិត ឬអ៊ីមែលណាមួយ។ |
| **Auto Locate Program**<br>*n.* | AUTO-LOC | កម្មវិធីតាំងទីកន្លែងដោយស្វ័យប្រវត្តិ | A Support Enforcement Management System (SEMS) program that automatically searches various Washington state agency databases for information on an individual. The program meets some of the federal locate requirements. **Cambodian –** កម្មវិធីប្រព័ន្ធគ្រប់គ្រងការអនុវត្តប្រាក់ឧបត្ថម្ភ **(SEMS)** ដែលធ្វើការស្រាវជ្រាវដោយស្វ័យប្រវត្តិនូវមូលដ្ឋានទិន្នន័យរបស់ទីភ្នាក់ងារខុសៗគ្នាជាច្រើននៃរដ្ឋវ៉ាស៊ីនតោន ដើម្បីស្វែងរកព័ត៌មានស្តីពីបុគ្គលណាម្នាក់។ កម្មវិធីនេះបំពេញតាមលក្ខខណ្ឌទីកន្លែងមួយចំនួនរបស់សហព័ន្ធ។ |
| **Automated Credit Reporting Program**<br>*n.* | | កម្មវិធីរាយការណ៍អំពីឥណទានដោយស្វ័យប្រវត្តិ | A SEMS computer process that automatically reports certain support debts to all major credit bureaus. The program reports total debt balance, current support due, and delinquency status of selected cases. **Cambodian –** ដំណើរការកុំព្យូទ័រ **SEMS** ដែលរាយការណ៍ដោយស្វ័យប្រវត្តិអំពីបំណុលនៃប្រាក់ឧបត្ថម្ភមួយចំនួនទៅកាន់ការិយាល័យឥណទានសំខាន់ៗទាំងអស់។ កម្មវិធីនេះរាយការណ៍អំពីសមតុល្យបំណុលសរុប ប្រាក់ឧបត្ថម្ភបច្ចុប្បន្នដែលដល់កំណត់បង់ និងស្ថានភាពនៃការសងប្រាក់ហួសកំណត់នៃរឿងក្តីនានាដែលបានជ្រើសរើស។ |

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Automated Payment Monitoring** *n.* | APMP | ការពិនិត្យតាមដានការទូទាត់ប្រាក់ដោយស្វ័យប្រវត្តិ | A SEMS program that staff can set to monitor whether timely payments are received on a case. The program triggers a review code for the RSEO when a payment is missed. **Cambodian –** កម្មវិធី **SEMS** ដែលបុគ្គលិកអាចធ្វើការកំណត់ដើម្បីពិនិត្យតាមដានថាតើការទូទាត់ ប្រាក់សម្រាប់រឿងក្តីមួយត្រូវបានទទួលយ៉ាងទាន់ពេលវេលាដែរឬទេ។ កម្មវិធីនេះ បង្កើតលេខកូដត្រួតពិនិត្យឡើងវិញសម្រាប់ **RSEO** នៅពេលមានការខកខាន មិនបានធ្វើការទូទាត់ប្រាក់ណាមួយ។ |
| **Automatic Enforcement Language** *n.* | | ភាសាអនុវត្តច្បាប់ស្វ័យប្រវត្តិ | Part of a support order that requires payments through Washington State Support Registry (WSSR) and warns the responsible parent that enforcement action may occur without further notice. It provides due process to the NCP so no further notice is needed. **Cambodian –** ភាគីនៃដីកាប្រាក់ឧបត្ថម្ភដែលតម្រូវឲធ្វើការទូទាត់ប្រាក់តាមរយៈ ការិយាល័យចុះបញ្ជីប្រាក់អាហារូបត្ថម្ភនៃរដ្ឋវ៉ាស៊ីនតោន **(WSSR)** និងព្រមានដល់ ឪពុក/ម្តាយដែលមានទំនួលខុសត្រូវដែលចំណាត់ការអនុវត្តច្បាប់អាចកើតឡើង ដោយពុំមានការជូនដំណឹងបន្ថែមទៀត។ សេចក្តីបង្គាប់នេះផ្តល់ដំណើរការនៃប្រាក់ ដែលដល់កំណត់បង់ដល់ **NCP** ដូច្នេះពុំចាំបាច់មានការជូនដំណឹងបន្ថែមទៀតនោះទេ។ |
| **Automatic Medical Enforcement Language** *n.* | | ភាសាអនុវត្តផ្នែកវេជ្ជសាស្ត្រស្វ័យប្រវត្តិ | Part of a support order telling the NCP that DCS will enforce medical enrollment directly with an employer/union without further notice to the NCP if the NCP fails to provide insurance within 20 days of its availability. It provides due process to the NCP so no further notice is needed. **Cambodian –** ភាគីនៃដីកាប្រាក់ឧបត្ថម្ភដែលប្រាប់ **NCP** ថា **DCS** នឹងអនុវត្តការចុះឈ្មោះចូលរួម ផ្នែកវេជ្ជសាស្ត្រដោយផ្ទាល់ជាមួយនិយោជក/សហជីពណាមួយដោយពុំមានការជូនដំណឹងបន្ថែមទៀតទៅកាន់ **NCP** ប្រសិនបើ **NCP** ខកខានមិនបានផ្តល់ការ ធានារ៉ាប់រងអំពីភាពអាចជួបបុគ្គលនោះបានក្នុងរយៈពេល **20** ថ្ងៃ។ ដីកានេះផ្តល់ ដំណើរការកាត់ក្តីដោយស្មើភាពដល់ **NCP** ដូច្នេះពុំចាំបាច់មានការជូនដំណឹងបន្ថែមទៀតនោះទេ។ |
| **Auto-Suspense** *n.* | | ការផ្អាកដោយស្វ័យប្រវត្តិ | A SEMS program that automatically applies payments from suspense to a case per the algorithm. **Cambodian –** កម្មវិធី **SEMS** ដែលអនុវត្តការទូទាត់ប្រាក់ដោយស្វ័យប្រវត្តិពីការផ្អាករឿងក្តីណាមួយតាមប្រព័ន្ធសំខ្យាអារ៉ាប់ **(algorithm)**។ |
| **Average** *adj.* | AVG | ចំនួនជាមធ្យម | Of, relating to, or being a mathematical average. **Cambodian –** ដែលពាក់ព័ន្ធនឹង ឬតាមចំនួនជាមធ្យមផ្នែកគណិតវិទ្យា។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Balance**<br>*n.* | BAL | សមតុល្យ | Equality of totals in the debit and credit sides of an account. The difference between such totals. **Cambodian –** សមភាពនៃចំនួនសរុបនៅក្នុងផ្នែកឥណពន្ធ និងឥណទាននៃគណនីណាមួយ។ ភាពខុសគ្នារវាងចំនួនសរុបបែបនោះ។ |
| **Bankrupt, Bankruptcy**<br>*n.* | BKPT | ក្ស័យធន ភាពក្ស័យធន | The situation when a debtor who petitions the court voluntarily or by his or her creditors is judged legally insolvent. **Cambodian –** ស្ថានភាពនៅពេលដែលកូនបំណុលណាម្នាក់ដែលមានពាក្យបណ្ដឹងដែលតុលាការបានធ្វើការវិនិច្ឆ័យដោយស្ម័គ្រចិត្ត ឬដោយម្ចាស់បំណុលរបស់គាត់ ឬនាងថា អសាធនតាមផ្លូវច្បាប់។ |
| **Basic Allowance for Quarters**<br>*n.* | BAQ | ប្រាក់ឧបត្ថម្ភកម្រិតមូលដ្ឋានតាមត្រីមាស | Supplemental income paid when a military member or the member's family lives outside of military housing. **Cambodian –** ប្រាក់ចំណូលបន្ថែមដែលត្រូវបានទូទាត់នៅពេលដែលសមាជិកយោធាណាម្នាក់ ឬគ្រួសាររបស់សមាជិកនោះរស់នៅខាងក្រៅទីលំនៅរបស់យោធា។ |
| **Basic Child Support Obligation**<br>*n.* | | កាតព្វកិច្ចប្រាក់អាហារូបត្ថម្ភកម្រិតមូលដ្ឋាន | The term the Washington State Child Support Schedule uses for the initial monthly support amount determined from the economic table. The basic support obligation is based only on the parties' combined net income and the number of children for whom support is sought. The amount does not include medical, day care, other special expenses or deviations considered in arriving at the final support amount. **Cambodian –** លក្ខខណ្ឌនៃកាលវិភាគរបស់ការិយាល័យចុះបញ្ជីប្រាក់អាហារូបត្ថម្ភនៃរដ្ឋវ៉ាស៊ីនតោន ប្រើប្រាស់សម្រាប់ចំនួនទឹកប្រាក់ឧបត្ថម្ភប្រចាំខែដំបូងដែលត្រូវបានកំណត់ពីតារាង សេដ្ឋកិច្ច។ កាតព្វកិច្ចប្រាក់ឧបត្ថម្ភកម្រិតមូលដ្ឋានផ្អែកតែលើការរួមបញ្ចូលគ្នារវាង ប្រាក់ចំណូលសុទ្ធរបស់គូភាគី និងចំនួនកូនដែលប្រាក់ឧបត្ថម្ភត្រូវបានស្នើសុំ។ ចំនួន ទឹកប្រាក់នេះមិនរួមបញ្ចូលចំណាយផ្នែកវេជ្ជសាស្ត្រ ចំណាយលើការថែទាំកុមារនៅ ពេលថ្ងៃ ចំណាយពិសេសៗផ្សេងៗទៀត ឬគម្លាតដែលត្រូវបានពិចារណាក្នុងការឈានដល់ចំនួនប្រាក់ឧបត្ថម្ភចុងក្រោយ។ |
| **Basic Food Assistance**<br>*n.* | | ជំនួយស្បៀងអាហារកម្រិតមូលដ្ឋាន | The DSHS IV-A program responsible for administering the federal United States Department of Agriculture program that provides food assistance/benefits to people in need. **Cambodian –** កម្មវិធី **DSHS IV-A** ទទួលខុសត្រូវចំពោះការគ្រប់គ្រងកម្មវិធីរបស់ក្រសួងកសិកម្ម នៃសហព័ន្ធសហរដ្ឋអាមេរិកដែលផ្ដល់ជំនួយផ្នែកស្បៀងអាហារ/ផលប្រយោជន៍ទានាដែលប្រជាជនដែលមានការខ្វះខាត។ |
| **Birth Costs**<br>*n.* | | សោហ៊ុយនៅពេលកើត | The prenatal, birthing and postnatal costs incurred either by the mother or the state. **Cambodian –** សោហ៊ុយលើការថែទាំមុនពេលសម្រាល ក្នុងអំឡុងពេលសម្រាលរបស់ម្ដាយ ឬ របស់រដ្ឋ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Blood Draw**<br>*adv.* | BD | ការបូមឈាម | The act of taking a blood sample. **Cambodian –** សកម្មភាពក្នុងការយកសំណាកឈាម។ |
| **Blood Test**<br>*n.* | BT | ការធ្វើតេស្តឈាម | The act of using a scientific method to determine the components of a blood sample. **Cambodian –** សកម្មភាពក្នុងការប្រើប្រាស់វិធីសាស្ត្រផ្នែកវិទ្យាសាស្ត្រដើម្បីកំណត់អំពីសមាសធាតុ របស់សំណាកឈាម។ |
| **Calculation**<br>*n.* | CALC | ការគណនា | A mathematical process used to count items like totaling payments. **Cambodian –** ដំណើរការផ្នែកគណិតវិទ្យាដែលត្រូវបានប្រើប្រាស់ដើម្បីរាប់វត្ថុនានាដូចជាការសរុបការទូទាត់ប្រាក់ជាដើម។ |
| **Call**<br>*v.* | | ហៅ | To use the telephone to talk with another person. **Cambodian –** ប្រើប្រាស់ទូរស័ព្ទដើម្បីនិយាយជាមួយបុគ្គលណាម្នាក់ផ្សេងទៀត។ |
| **Care Of**<br>*adv. ph.* | C/O | ថែទាំ | A term used to deliver items to persons at another person's or business' address: to mail in care of. **Cambodian –** លក្ខខណ្ឌដែលត្រូវបានប្រើប្រាស់ដើម្បីប្រគល់វត្ថុនានាទៅកាន់បុគ្គលទាំងឡាយនៅអាសយដ្ឋានរបស់បុគ្គល ឬអាជីវកម្មណាមួយផ្សេងទៀត ៖ ផ្ញើសំបុត្រតាមរយៈ។ |
| **Case Closure**<br>*v.* | | ការបិទរឿងក្តី | When DCS closes an open case when it meets federal and state closure criteria. **Cambodian –** នៅពេលដែល **DCS** បិទរឿងក្តីដែលកំពុងបើកមួយនៅពេលដែលខ្លួនបំពេញតាមលក្ខណៈវិនិច្ឆ័យបិទរបស់សហព័ន្ធ និងរបស់រដ្ឋ។ |
| **Case Disbursement History**<br>*n.* | DH | ប្រវត្តិបញ្ចេញរឿងក្តី | Displays a specific case record showing the issuance of each check associated with that case. This includes the check number, date and check status. The screen also records any disbursements over grant sent to a Custodial Parent. **Cambodian –** បង្ហាញកំណត់ត្រាអំពីរឿងក្តីជាក់លាក់ណាមួយដែលបង្ហាញអំពីការចេញ មូលប្បទានបត្រនីមួយៗដែលពាក់ព័ន្ធនឹងរឿងក្តីនោះ។ នេះរួមបញ្ចូលទាំងលេខ មូលប្បទានបត្រ កាលបរិច្ឆេទ និងស្ថានភាពរបស់មូលប្បទានបត្រផងដែរ។ ស្ក្រីនក៏កត់ត្រាអំពីការបញ្ចេញប្រាក់លើសពីការផ្តល់ជូនណាមួយទៅកាន់ឪពុក/ម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ផងដែរ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Case Payment History** *n.* | CH | ប្រវត្តិទូទាត់សម្រាប់រឿងក្តី | This SEMS screen displays the individual payments processed to a specific case and the distribution of those payments within a case. Transactions include noncustodial parent payments and adjustments. **Cambodian –** ស្រ្កីន **SEMS** បង្ហាញអំពីការទូទាត់ប្រាក់រៀងៗខ្លួនដែលបានដំណើរការទៅកាន់រឿងក្តីជាក់លាក់ណាមួយ និងការបែងចែងការទូទាត់ប្រាក់ទាំងនោះទៅកាន់នៅក្នុងរឿងក្តីណាមួយ។ ប្រតិបត្តិការរួមបញ្ចូលការទូទាត់ប្រាក់ និងការសម្រួលរបស់ឪពុក/ ម្តាយដែលពុំមានសិទ្ធិចិញ្ចឹមបីបាច់។ |
| **Center for Health Statistics** *n.* | CHS | មជ្ឈមណ្ឌលស្ថិតិសុខាភិបាល | Formerly the Office of Vital Records, CHS is the part of the Department of Health that maintains birth certificates and paternity affidavits. **Cambodian –** អតីតការិយាល័យអត្រានុកូដ្ឋាន **CHS** គឺជាផ្នែកមួយនៃក្រសួងសុខាភិបាល ដែលថែរក្សាសំបុត្រកំណើត និងលិខិតស្បថសច្ចាអំពីបិតុភាព។ |
| **Central Registry** *n.* | | ការិយាល័យចុះបញ្ជីកណ្តាល | A unit in DCS's state office that processes court orders from county clerks and requests from other states for enforcement and locate. Central Registry is responsible for three types of cases not managed by field offices: locate-only, Payment Services Only (PSO) and enforcement. **Cambodian –** ផ្នែកមួយនៅក្នុងការិយាល័យរដ្ឋរបស់ **DCS** ដែលដំណើរការដីកាតុលាការពី ក្រឡាបញ្ជីខោនធីនានា នឹងសំណើពីរដ្ឋផ្សេងទៀតសម្រាប់ការអនុវត្តច្បាប់ និងការកំណត់ទីតាំង។ ការិយាល័យចុះបញ្ជីកណ្តាលទទួលខុសត្រូវចំពោះ រឿងក្តីបីប្រភេទដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យតាមផ្នែកនានា ៖ តែការតាំងទីកន្លែងប៉ុណ្ណោះ, សេវាទូទាត់ប្រាក់តែប៉ុណ្ណោះ **(PSO)** និងការអនុវត្តច្បាប់។ |
| **Certification of Birth Record** *n.* | | សៀវភៅបញ្ជាក់កំណើត | A statement provided to DCS by the Center for Health Statistics verifying that the father of the child has signed a Paternity Acknowledgment, DOH/CHS 021. **Cambodian –** សេចក្តីថ្លែងការណ៍ដែលត្រូវបានផ្តល់ជូន **DCS** ដោយមជ្ឈមណ្ឌលស្ថិតិសុខាភិបាល ផ្ទៀងផ្ទាត់ថាឪពុករបស់កុមារបានចុះហត្ថលេខាលើការទទួលស្គាល់បិតុភាព **DOH/CHS 021** |
| **Certified Mail** *n.* | CM | សំបុត្រដែលមានការបញ្ជាក់ | Mail that documents the date it is received. **Cambodian –** ផ្ញើឯកសារនោះតាមប្រៃសណីយ៍នៅកាលបរិច្ឆេទដែលបានទទួលឯកសារនោះ។ |
| **Certified Mail, Return Receipt** *n.* | CMRR | សំបុត្រដែលមានការបញ្ជាក់, ការបញ្ជាក់ការទទួលបាន | Mail that documents the date it is received and requires the receiver to sign proving it was received. **Cambodian –** ផ្ញើឯកសារនោះតាមប្រៃសណីយ៍នៅកាលបរិច្ឆេទដែលបានទទួលឯកសារនោះ និងតម្រូវឱ្យអ្នកទទួលចុះហត្ថលេខាបញ្ជាក់ថាខ្លួនបានទទួលឯកសារនោះ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Certify, Certified, Certification** *v.* | CERT | បញ្ជាក់, បានបញ្ជាក់, ការបញ្ជាក់ | To certify formally in writing as true, accurate or genuine. **Cambodian –** បញ្ជាក់ជាលាយលក្ខណ៍អក្សរជាផ្លូវការថាពិត ត្រឹមត្រូវ ឬពិតប្រាកដ។ |
| **Change** *v.* | CHG | ផ្លាស់ប្តូរ | To make different. To reverse an opinion or a decision. See: Modify. **Cambodian –** ធ្វើឲមានភាពខុសប្លែកគ្នា។ ធ្វើការជំទាស់នឹងគំនិត ឬសេចក្តីសម្រេចណាមួយ។ ចូរមើល ៖ ធ្វើការកែប្រែ។ |
| **Check** *n.* | CK | មូលប្បទានបត្រ | A written order to a bank to pay the amount specified from funds on deposit. **Cambodian –** សេចក្តីបង្គាប់ជាលាយលក្ខណ៍អក្សរទៅកាន់ធនាគារឲធ្វើការទូទាត់ចំនួនទឹកប្រាក់ ដែលបានបញ្ជាក់ពីមូលនិធិប្រាក់បញ្ញើ។ |
| **Child** *n.* | CH | កូន/កុមារ | A baby, infant, son or daughter. A person between birth and 18 years of age. **Cambodian –** កូនង៉ែត ទារក កូនប្រុស ឬកូនស្រី។ បុគ្គលណាម្នាក់នៅចន្លោះពេលចាប់កំណើត រហូតដល់មានអាយុ **18** ឆ្នាំ។ |
| **Child Support Enforcement** *n.* | CSE | ការអនុវតប្រាក់អាហារូបត្ថម្ភ | The money paid to take care of children's needs: food, clothing, housing and nurturing. **Cambodian –** ប្រាក់ដែលបានទូទាត់ដើម្បីធ្វើការថែទាំតាមតម្រូវការរបស់កុមារ ៖ ចំណីអាហារ សម្លៀកបំពាក់ ទីលំនៅ និងការអប់រំបណ្តុះបណ្តាល។ |
| **Child Support (Current Support)** *n.* | CS | ប្រាក់អាហារូបត្ថម្ភ (ប្រាក់ឧបត្ថម្ភនាពេលបច្ចុប្បន្ន) | The amount of money paid each month for child support. **Cambodian –** ចំនួនទឹកប្រាក់ដែលបានទូទាត់ជារៀងរាល់ខែសម្រាប់ថ្លៃអាហារូបត្ថម្ភ។ |
| **Child Protective Service** *n.* | CPS | សេវាការពារកុមារ | The Washington state office that oversees child abuse incidents. **Cambodian –** ការិយាល័យរដ្ឋវ៉ាស៊ីនតោនដែលត្រួតពិនិត្យហេតុការណ៍ដែលបំពានលើកុមារ។ |
| **Child Support Enforcement Program** *n.* | CSEP | កម្មវិធីអនុវតប្រាក់អាហារូបត្ថម្ភ | The federal and state programs that oversee the collection of child support. **Cambodian –** កម្មវិធីរបស់សហព័ន្ធ និងរបស់រដ្ឋដែលត្រួតពិនិត្យការប្រមូលប្រាក់អាហារូបត្ថម្ភ។ |
| **Claims Officer** *n.* | CL/OF | មន្ត្រីផ្នែកទាមទារ | A DCS attorney. **Cambodian –** មេធាវីរបស់ **DCS**។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Clerk**<br>*n.* | CLK | ក្រឡាបញ្ជី | A person who keeps the records and performs the regular business of a legislative body or court. **Cambodian –** បុគ្គលដែលថែរក្សាកំណត់ត្រា និងធ្វើអាជីវកម្មធម្មតារបស់អង្គភាពនីតិកម្ម ឬតុលាការ។ |
| **Code of Federal Regulations**<br>*n.* | CFR | លេខកូដនៃបទប្បញ្ញត្តិសហព័ន្ធ | The compiled rules and regulations adopted by the executive departments and agencies of the federal government. **Cambodian –** វិធាន និងបទប្បញ្ញត្តិដែលត្រូវបានចងក្រងទុក ត្រូវបានអនុម័តដោយក្រសួង និងទីភ្នាក់ងារនានានៃនីតិប្រតិបត្តិរបស់រដ្ឋាភិបាលសហព័ន្ធ។ |
| **Collection Action**<br>*n.* | | ចំណាត់ការប្រមូល | Any of the administrative or court-ordered collection remedies available to DCS to enforce a support order, such as withholding actions, liens, and referrals for contempt of court. **Cambodian –** ដំណោះស្រាយសម្ងហភាពផ្នែករដ្ឋបាល ឬតាមដីកាតុលាការណាមួយអាចរកបាន សម្រាប់ **DCS** ក្នុងការអនុវត្តដីកាប្រាក់ឧបត្ថម្ភ ដូចជាចំណាត់ការកាត់ទុក សិទ្ធិឃាត់ទុក និងការយោងដល់ទោសសម្រាប់ការមើលងាយតុលាការ។ |
| **Community Relations Unit**<br>*n.* | CRU | អង្គភាពទំនាក់ទំនងសហគមន៍ | DCS staff who answer customer questions and handle complaints. **Cambodian –** បុគ្គលិក **DCS** ដែលឆ្លើយតបនឹងសំណួររបស់អតិថិជន និងដោះស្រាយការរិះគន់នានា។ |
| **Community Services Office**<br>*n.* | CSO | ការិយាល័យសេវាសហគមន៍ | The DSHS office that provides public assistance (TANF), Basic Food/SNAP benefits and other services. **Cambodian –** ការិយាល័យ **DSHS** ដែលផ្តល់ជំនួយសាធារណៈ **(TANF)** ស្បៀងអាហារកម្រិត មូលដ្ឋាន/ផលប្រយោជន៍ **SNAP** និងសេវាដទៃទៀត។ |
| **Conference Board**<br>*n.* | CBD | ក្រុមប្រឹក្សាសន្និបាត | An informal meeting to determine facts and attempt to resolve grievances when an individual disagrees with DCS actions. A Claims Officer from DCS state office (not an Administrative Law Judge) hears and settles the issue. **Cambodian –** កិច្ចប្រជុំមិនផ្លូវការមួយដើម្បីកំណត់ការពិត និងមានបំណងដោះស្រាយបណ្តឹងតវ៉ា នៅពេលដែលបុគ្គលណាម្នាក់មិនយល់ស្របចំពោះចំណាត់ការនានារបស់ **DCS**។ មន្ត្រីផ្នែកទាមទារប្រាក់ម្នាក់ដែលមកពីការិយាល័យ **DCS** (មិនមែនជាចៅក្រមនៃ ច្បាប់រដ្ឋបាលនោះទេ) បើកសវនាការ និងដោះស្រាយបញ្ហា។ |
| **Confidential Shelter**<br>*n.* | | ជម្រកអាថ៌កំបាំង | A secret or undisclosed place providing protection or refuge to a person in a violent relationship. **Cambodian –** ទីកន្លែងអាថ៌កំបាំង ឬទីកន្លែងដែលមិនបានលាតត្រដាង ដែលផ្តល់ការការពារ ឬផ្តល់ទីជម្រកដល់បុគ្គលដែលស្ថិតនៅទំនាក់ទំនងដែលប្រើអំពើហិង្សា។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Consent Order**<br>*n.* | | ដីកាដែលមានការយល់ព្រម | A negotiated settlement of current support and arrears that is signed by an Administrative Law Judge.<br>A Consent Order is an administrative order. **Cambodian –** ការដោះស្រាយដែលបានចរចាគ្នាអំពីប្រាក់ឧបត្ថម្ភបច្ចុប្បន្ន និងប្រាក់ទូទាត់តាមក្រោយដែលត្រូវបានចុះហត្ថលេខាដោយចៅក្រមនៃច្បាប់រដ្ឋបាលណាម្នាក់។ ដីកាដែលមានការយល់ព្រមមួយច្បាប់ គឺជាដីកាផ្នែករដ្ឋបាល។ |
| **Contempt of Court**<br>*n.* | | ការមើលងាយតុលាការ | When the court finds that there is a failure to follow a child support order. **Cambodian –** នៅពេលដែលតុលាការរកឃើញថាមានខកខានមិនបានអនុវត្តតាមដីកាប្រាក់អាហារូបត្ថម្ភ។ |
| **Continuance**<br>*n.* | | ផាបន្ត | The postponement of an action pending in court or other adjudicative proceeding. **Cambodian –** ការពន្យារពេលចំពោះចំណាត់ការណាមួយដែលរង់ចាំការវិនិច្ឆ័យនៅក្នុងតុលាការ ឬដំណើរការរឿងក្តីបែបវិនិច្ឆ័យផ្សេងទៀត។ |
| **Cooperation, Cooperative**<br>*n.* | COOP | កិច្ចសហប្រតិបត្តិការ | As a condition of eligibility for financial assistance, the Custodial Parent (CP) must assign child support rights to the state, provide relevant information that the CP either knows or can obtain at no cost, and assist in establishing/enforcing child support. **Cambodian –** ដែលជាលក្ខខណ្ឌមួយនៃសិទ្ធិទទួលបានជំនួយផ្នែកហិរញ្ញវត្ថុ ឪពុក/ម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ **(CP)** ត្រូវតែធ្វើអនុប្បទានសិទ្ធិទទួលបានប្រាក់អាហារូបត្ថម្ភទៅឲ រដ្ឋ ផ្តល់ព័ត៌មានពាក់ព័ន្ធដែលដឹង ឬអាចបានទទួលដោយឥតគិតថ្លៃ និងជួយបង្កើត/អនុវត្តប្រាក់អាហារូបត្ថម្ភ។ |
| **Court**<br>*n.* | CT | តុលាការ | A person or group of persons whose task is to hear and submit a decision on cases of law. **Cambodian –** បុគ្គលណាម្នាក់ ឬមនុស្សមួយក្រុមដែលកិច្ចការរបស់ពួកគេ គឺការបើកសវនាការ និងដាក់ជូនទូវសេចក្តីសម្រេចចំពោះរឿងក្តីនានាតាមច្បាប់។ |
| **Court Order**<br>*n.* | CTO | ដីកាតុលាការ | A document signed by a judge or court commissioner in a court of law and enforceable by the parties to the action. Court orders supersede administrative orders in most instances. **Cambodian –** ឯកសារដែលបានចុះហត្ថលេខាដោយចៅក្រម ឬស្នងការតុលាការនៅក្នុងតុលាការ ណាមួយ និងអាចអនុវត្តបានដោយគូភាគីនៃចំណាត់ការនោះ។ ដីកាតុលាការជំនួសឲដីកាផ្នែករដ្ឋបាលនៅក្នុងហេតុការណ៍ភាគច្រើន។ |

# Division of Child Support

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Credit Bureau**<br>*n.* | CRBU | ការិយាល័យឥណទាន | A consumer reporting agency engaged in assembling or evaluating consumer information and furnishing credit reports to third parties for a fee, dues or on a cooperative nonprofit basis. **Cambodian –** ទីភ្នាក់ងាររាយការណ៍អំពីអតិថិជនបានចូលរួមនៅក្នុងការប្រមូលផ្តុំ ឬវាយតម្លៃអំពី ព័ត៌មានរបស់អ្នកប្រើប្រាស់ និងផ្តល់របាយការណ៍ឥណទានទៅកាន់តតិយជន សម្រាប់ប្រាក់កម្រៃ ប្រាក់ដែលដល់កំណត់បង់ ឬតាមមូលដ្ឋាននៃការមិនស្វែងរក ប្រាក់ចំណេញរបស់សាជីវកម្ម។ |
| **Current Order**<br>*n.* | | ដីកាបច្ចុប្បន្ន | The support order that is the basis of current collections by DCS. **Cambodian –** ដីកាប្រាក់ឧបត្ថម្ភដែលជាមូលដ្ឋាននៃការប្រមូលប្រាក់ដោយ **DCS** នាពេលបច្ចុប្បន្ន។ |
| **Current and Future Support**<br>*n.* | CFS | ប្រាក់ឧបត្ថម្ភនាពេលបច្ចុប្បន្ន និងអនាគត | The amount of support due each month, but not yet past due. **Cambodian –** ចំនួនប្រាក់ឧបត្ថម្ភដែលដល់កំណត់បង់សម្រាប់ខែនីមួយៗ ប៉ុន្តែមិនទាន់ហួសកំណត់។ |
| **Custodial Parent**<br>*n.* | CP | ឪពុក/ម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ | The parent with whom the child resides most of the time. This parent generally is entitled to support payments on behalf of the child. **Cambodian –** ឪពុក/ម្តាយដែលកូនស្នាក់នៅជាមួយច្រើនជាងគេ។ ឪពុក/ម្តាយនេះ ជាទូទៅ មាន ទទួលបានប្រាក់ឧបត្ថម្ភតាងនាមឲ្យកូន។ |
| **Custodian, Custodial**<br>*n.* | CUST | អ្នកដែលមានសិទ្ធិចិញ្ចឹមបីបាច់, ដែលមានសិទ្ធិចិញ្ចឹមបីបាច់ | A parent or other adult with whom the child lives. **Cambodian –** ឪពុក/ម្តាយ ឬមនុស្សពេញវ័យដទៃទៀតដែលកុមាររស់នៅជាមួយ។ |
| **Custody**<br>*n.* | | សិទ្ធិចិញ្ចឹមបីបាច់ | The act of caring for a child or right granted by a court or parent. **Cambodian –** សកម្មភាពមើលថែទាំកុមារ ឬសិទ្ធិដែលត្រូវបានប្រគល់ជូនដោយតុលាការ ឬឪពុក/ ម្តាយណាម្នាក់។ |
| **Custodial Stepparent**<br>*n.* | | ឪពុក/ម្តាយចុងដែលមានសិទ្ធិចិញ្ចឹមបីបាច់ | Stepparent relationship exists when an individual marries the child's parent. The custodial stepparent relationship exists when the stepparent has lived in the home with the child and the parent during periods when the child was considered a permanent resident of the household. **Cambodian –** ទំនាក់ទំនងឪពុក/ម្តាយចុងកើតឡើងនៅពេលដែលបុគ្គលណាម្នាក់រៀបការជាមួយ ឪពុក/ម្តាយរបស់កុមារ។ ទំនាក់ទំនងឪពុក/ម្តាយចុងដែលមិនសិទ្ធិចិញ្ចឹមបីបាច់កើតឡើងនៅពេលដែលឪពុក/ម្តាយចុងបានរស់នៅជាមួយកូន និងឪពុក/ម្តាយក្នុងអំឡុង ពេលដែលកូនត្រូវបានចាត់ទុកថាជានិវាសនជនអចិន្ត្រៃយ៍របស់គ្រួសារនោះ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Date of Birth**<br>*n.* | DOB | ថ្ងៃខែឆ្នាំកំណើត | The day a child is born. **Cambodian –** ថ្ងៃដែលកុមារចាប់កំណើត។ |
| **Date Of Conception, Document**<br>*n.* | DOC | ថ្ងៃខែឆ្នាំចាប់កំណើត, ឯកសារ | The day a child was conceived. **Cambodian –** ថ្ងៃដែលកុមារមានវត្តមាននៅពោះម្តាយ។ |
| **DCS Card**<br>*n.* | | ប័ណ្ណ DCS | A VISA Card. Child support payments are electronically put on the card by DCS instead of issuing checks for child support payments. **Cambodian –** វីសាកាត។ ការទូទាត់ប្រាក់អាហារូបត្ថម្ភត្រូវបានកត់ត្រាទុកតាមប្រព័ន្ធអេឡិចត្រូនិច នៅលើកាត ដោយ **DCS** ជំនួសឲការចេញមូលប្បទានបត្រសម្រាប់ការទូទាត់ប្រាក់អាហារូបត្ថម្ភ។ |
| **Debt Calculation**<br>*n.* | Debt Calc | ការគណនាបំណុល | A computation to determine the amount of child support owed. **Cambodian –** ការគណនាតាមកុំព្យូទ័រដើម្បីកំណត់ចំនួនប្រាក់អាហារូបត្ថម្ភដែលនៅជំពាក់។ |
| **Declaration**<br>*n.* | | សេចក្តីប្រកាស | A formal statement listing facts and information about a person's finances or actions. **Cambodian –** សេចក្តីថ្លែងការណ៍ជាផ្លូវការមួយដែលរៀបរាប់អំពីការពិត និងព័ត៌មានស្តីពីហិរញ្ញវត្ថុ ឬចំណាត់ការនានារបស់បុគ្គលណាម្នាក់។ |
| **Decree of Divorce, Decree of Dissolution**<br>*n.* | DD | ក្រឹត្យស្តីការលែងលះ, ក្រឹត្យស្តីការរំលាយ | The legal termination of a marriage. **Cambodian –** ការបញ្ចប់អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ |
| **Default Order**<br>*n.* | | ដីកាស្តីពីការមិនបានបំពេញតាមកាតព្វកិច្ច | A court order decision made when a person fails to appear in court when ordered. **Cambodian –** សេចក្តីសម្រេចរបស់ដីកាតុលាការត្រូវបានធ្វើឡើងនៅពេលដែលបុគ្គលណាម្នាក់ ខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខតុលាការនៅពេលដែលមានដីកាបង្គាប់ឲ ចូលខ្លួន។ |
| **Delinquency**<br>*n.* | | ពិរុទ្ធភាព | A late payment or failing to do what is required by law or obligation. **Cambodian –** ការទូទាត់ប្រាក់យឺត ឬការខកខានមិនបានធ្វើអ្វីដែលត្រូវបានតម្រូវដោយច្បាប់ ឬកាតព្វកិច្ច។ |
| **Department of Health**<br>*n.* | DOH | ក្រសួងសុខាភិបាល | The Washington state office that oversees birth records. **Cambodian –** ការិយាល័យរដ្ឋវ៉ាស៊ីនតោនដែលត្រួតពិនិត្យកំណត់ត្រាកំណើត។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Department of Health and Human Services** *n.* | DHHS | ក្រសួងសេវាសុខាភិបាល និងសេវាមនុស្ស | The federal office that oversees DSHS. **Cambodian –** ការិយាល័យសហព័ន្ធដែលត្រួតពិនិត្យ **DSHS**។ |
| **Department of Social and Health Services** *n.* | DSHS | ក្រសួងសេវាសង្គម និងសេវាសុខាភិបាល | The Washington state agency that oversees the management of public assístance, child support, foster care and other programs. **Cambodian –** ទីភ្នាក់ងាររដ្ឋវ៉ាស៊ីនតោនដែលត្រួតពិនិត្យការគ្រប់គ្រងជំនួយសាធារណៈ ប្រាក់អាហារូបត្ថម្ភ ការចិញ្ចឹមថែទាំ និងកម្មវិធីដទៃទៀត។ |
| **Dependent Child** *n.* | DEP | កូនក្នុងបន្ទុក | A child who relies on another for support. **Cambodian –** កុមារដែលពឹងផ្អែកលើមនុស្សម្នាក់ផ្សេងទៀតសម្រាប់ប្រាក់ឧបត្ថម្ភ។ |
| **Determination of Parentage** *n.* | | ការកំណត់ភាពជាឪពុកម្តាយ | The establishment of the parent-child relationship by the signing of a valid acknowledgement of paternity. **Cambodian –** ការបង្កើតទំនាក់ទំនងឪពុក/ម្តាយ-កុមារតាមរយៈការចុះហត្ថលេខាទទួលស្គាល់ បិតុភាពដែលមានសុពលភាព។ |
| **Deviation** *n.* | DEV | គម្លាត | A child support amount that differs from the standard calculation according to the Washington State Child Support Schedule. **Cambodian –** ចំនួនប្រាក់អាហារូបត្ថម្ភដែលខុសពីការគណនាស្តង់ដារយោងតាមកាលវិភាគប្រាក់អាហារូបត្ថម្ភរបស់រដ្ឋវ៉ាស៊ីនតោន។ |
| **Direct Deposit** *n.* | | ការដាក់ប្រាក់ដោយផ្ទាល់ | The act of electronically transferring money from DCS into a custodial parent's bank account. **Cambodian –** សកម្មភាពនៃការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិចពី **DCS** ទៅកាន់គណនីធនាគារ របស់ឪពុក/ម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ណាម្នាក់។ |
| **Disposable Earnings** *n.* | | ប្រាក់ចំណូលក្រោយការកាត់កង | The amount of earnings after deductions are withheld, like Social Security, Medicare, medical insurance and others. Also called net earnings or take-home pay. **Cambodian –** ចំនួនទឹកប្រាក់ដែលទទួលបានបន្ទាប់ពីមានការកាត់ប្រាក់នានាត្រូវបានកាត់ទុក ដូចជា ផ្នែកសន្តិសុខសង្គម, **Medicare,** ការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រនិងផ្នែក ផ្សេងៗទៀត។ ក៏ត្រូវបានហៅថាជាប្រាក់ចំណូលសុទ្ធ ឬប្រាក់យកត្រឡប់ទៅផ្ទះវិញផងដែរ។ |
| **Distribute, Distributor, Distribution** *n.* | DISTR | ចែកចាយ, អ្នកចែកចាយ, ការចែកចាយ | The DCS Cash process that applies payments to cases. **Cambodian –** ដំណើរការសាច់ប្រាក់របស់ **DCS** ដែលធ្វើការទូទាត់ប្រាក់ទៅកាន់រឿងក្តីនានា។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Division of Children & Family Services** *n.* | DCFS | ផ្នែកសេវាកុមារ និងគ្រួសារ | A program within DSHS that administers programs for children in foster care and those being adopted. **Cambodian –** កម្មវិធីមួយនៅក្នុង **DSHS** ដែលគ្រប់គ្រងកម្មវិធីនានាសម្រាប់កុមារដែលស្ថិតនៅក្នុង ការចិញ្ចឹមថែទាំ និងកុមារដែលត្រូវបានទទួលចិញ្ចឹម។ |
| **Division of Child Support** *n.* | DCS | ផ្នែកប្រាក់អាហារូបត្ថម្ភ | A program within DSHS that collects child support and processes payments. DCS also enforces medical support and daycare costs. **Cambodian –** កម្មវិធីមួយនៅក្នុង **DSHS** ដែលប្រមូលប្រាក់អាហារូបត្ថម្ភ និងដំណើរការការទូទាត់ប្រាក់។ **DCS** ក៏អនុវត្តប្រាក់ឧបត្ថម្ភផ្នែកវេជ្ជសាស្ត្រ និងសោហ៊ុយលើការថែទាំកុមារ នៅពេលថ្ងៃផងដែរ។ |
| **Division of Developmental Disabilities** *n.* | DDD | ផ្នែកពិការភាពនៃការអភិវឌ្ឍ | A program within DSHS that administers programs to help disabled persons. **Cambodian –** កម្មវិធីមួយនៅក្នុង **DSHS** ដែលគ្រប់គ្រងកម្មវិធីនានាដើម្បីជួយជនពិការ។ |
| **Division of Fraud Investigation** *n.* | DFI | ផ្នែកស៊ើបអង្កេតអំពីការក្លែងបន្លំ | The DSHS division that investigates public assistance fraud. **Cambodian –** ផ្នែក **DSHS** ដែលស៊ើបអង្កេតការក្លែងបន្លំជំនួយសាធារណៈ។ |
| **Division of Vocational Rehabilitation** *n.* | DVR | ផ្នែកស្តារនីតិសម្បទាវិជ្ជាជីវៈ | A program within DSHS that administers programs to help people return to work after an injury or illness. **Cambodian –** កម្មវិធីមួយនៅក្នុង **DSHS** ដែលគ្រប់គ្រងកម្មវិធីនានាដើម្បីជួយបុគ្គលដែលត្រឡប់ចូលបម្រើការងារវិញបន្ទាប់ពីបានរងរបួស ឬមានជំងឺ។ |
| **Divorce** *n.* | DIV | ការលែងលះ | The legal dissolution of a marriage. **Cambodian –** ការរំលាយអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ |
| **Dollars, Money** *n.* | $ | ដុល្លារ, ប្រាក់ | Currency used as a medium of exchange. **Cambodian –** រូបិយប័ណ្ណដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការផ្លាស់ប្តូរ។ |
| **Donor** *n.* | | ម្ចាស់ជំនួយ | A person who produces eggs or sperm used for reproduction. **Cambodian –** បុគ្គលដែលផលិតស៊ុត ឬមេជីវិតដែលប្រើប្រាស់សម្រាប់ការបន្តពូជ។ |
| **Domestic Violence** *n.* | DV | អំពើហិង្សាក្នុងគ្រួសារ | Physical abuse and threats by one person in a family against another. **Cambodian –** ការបំពានផ្នែករាងកាយ និងការគម្រាមកំហែងដោយបុគ្គលណាម្នាក់នៅក្នុងគ្រួសារ ប្រឆាំងនឹងបុគ្គលណាម្នាក់ផ្សេងទៀត។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Due Process**<br>*n.* | | ដំណើរការកាត់ក្ដីដោយស្មើភាព | A course of action that protects a person's legal rights. **Cambodian –** ដំណើរការនៃចំណាត់ការដែលការពារសិទ្ធិស្របច្បាប់របស់បុគ្គលណាម្នាក់។ |
| **Earliest Accrued Arrears**<br>*n.* | EAA | ការទូទាត់ប្រាក់តាមក្រោយដែលបានបង្គរនាពេលថ្មីៗបំផុត | The oldest debt collectible under the statute of limitations. **Cambodian –** បំណុលចាស់បំផុតដែលអាចប្រមូលបានយោងច្បាប់នៃចំនួនកំណត់។ |
| **Earnings**<br>*n.* | | ប្រាក់ចំណូល | Compensation paid or payable for services: wages, salary, commissions and bonuses. **Cambodian –** សំណងដែលបានទូទាត់រួច និងដល់កំណត់ទូទាត់សម្រាប់សេវានានា ៖ ប្រាក់ឈ្នួល ប្រាក់បៀវត្សរ៍ ប្រាក់កម្រៃជើងសារ និងប្រាក់រង្វាន់។ |
| **Economic Services Administration**<br>*n.* | ESA | រដ្ឋបាលសេវាសេដ្ឋកិច្ច | An administration in DSHS that administers DCS and CSD. **Cambodian –** រដ្ឋបាលនៅក្នុង **DSHS** ដែលគ្រប់គ្រង **DCS** និង **CSD**។ |
| **Electronic Birth Certificate System**<br>*n.* | EBC | ប្រព័ន្ធសំបុត្រកំណើតអេឡិចត្រូនិច | Computer program that allows hospitals in Washington state to create a birth certificate electronically and transmit the completed birth certificate to the Center for Health Statistics (CHS). **Cambodian –** កម្មវិធីកុំព្យូទ័រដែលអនុញ្ញាតឲមន្ទីរពេទ្យនៅក្នុងរដ្ឋវ៉ាស៊ីនតោនធ្វើការបង្កើតសំបុត្រ កំណើតតាមប្រព័ន្ធអេឡិចត្រូនិច និងផ្ញើរសំបុត្រកំណើតដែលបានបំពេញរួចទៅកាន់ មជ្ឈមណ្ឌលស្ថិតិសុខាភិបាល **(CHS)**។ |
| **Electronic Funds Transfer**<br>*n.* | EFT | ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច | The computerized process of moving money from DCS to a bank or from a bank to DCS. **Cambodian –** ដំណើរការគណនាតាមប្រព័ន្ធកុំព្យូទ័រនូវប្រាក់ដែលបង្វិលចេញពី **DCS** ទៅកាន់ ធនាគារណាមួយ ឬចេញពីធនាគារណាមួយទៅកាន់ **DCS**។ |
| **Emancipated Child**<br>*n.* | | កូនដែលមិនស្ថិតនៅក្រោមអាណាព្យាបាលភាព | A child under 18 years of age who is no longer subject to parental control. **Cambodian –** កុមារដែលមានអាយុក្រោម **18** ឆ្នាំដែលឈប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អាណាព្យាបាលបន្តទៀតហើយ។ |
| **Employee**<br>*n.* | | និយោជិត | A person to whom an employer is paying, owes or expects to pay earnings in exchange for services orwork performed for the employer. **Cambodian –** បុគ្គលដែលនិយោជកកំពុងទូទាត់ប្រាក់ឲ ជំពាក់ប្រាក់ ឬរំពឹងថានឹងទូទាត់ប្រាក់ចំណូលជាថ្នូរនឹងសេវានឹង ឬការបម្រើការងារជូននិយោជកនោះ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Employment**<br>*n.* | | ការងារ | Services performed for earnings.<br>**Cambodian –** សេវាដែលត្រូវបានអនុវត្តដើម្បីទទួលបានប្រាក់ចំណូល។ |
| **Enclosed,**<br>*v.*<br>**Enclosure**<br>*n.* | ERP | បានភ្ជាប់<br>ការភ្ជាប់ | Something that is put in an envelope with a letter.<br>**Cambodian –** អ្វីមួយដែលដាក់នៅក្នុងស្រោមសំបុត្រជាមួយសំបុត្រ។ |
| **Enforce,**<br>**Enforcement**<br>*v.* | ENF | អនុវត្ត, ការអនុវត្ត | To force someone to act or obey (as under law).<br>**Cambodian –** បង្ខំឲអ្នកណាម្នាក់ធ្វើសកម្មភាព ឬគោរព (យោងតាមច្បាប់)។ |
| **English-**<br>**language**<br>**Learner**<br>*n.* | ELL | អ្នករៀនភាសាអង់គ្លេស | This refers to people with limited English abilities.<br>**Cambodian –** នេះសំដៅដល់បុគ្គលដែលមានសមត្ថភាពភាសា អង់គ្លេសនៅមានកម្រិត។ |
| **Established**<br>*v.* | EST | បានបង្កើតឡើង | To cause to be recognized and accepted often because of a law. **Cambodian –** ធ្វើឲមានការទទួលស្គាល់ និងទទួលយក តែងតែកើតឡើងដោយសារច្បាប់ណាមួយ។ |
| **Expenses**<br>*n.* | EXP | ចំណាយ | Money allotted for a payment.<br>**Cambodian –** ប្រាក់លៃទុកសម្រាប់ទូទាត់។ |
| **Extraordinary**<br>**Health Care**<br>**Expense**<br>*n.* | | ចំណាយលើការថែទាំ<br>សុខភាពវិសាមញ្ញ | Monthly health care expenses that exceed five percent of the basic child support obligation. **Cambodian –** ចំណាយលើការថែទាំសុខភាពប្រចាំខែដែលលើសពីប្រាំភាគរយនៃកាតព្វកិច្ចទូទាត់ប្រាក់អាហារូបត្ថម្ភកម្រិតមូលដ្ឋាន។ |
| **Family**<br>*n.* | FAM | គ្រួសារ | The person or persons on whose behalf support is asked, including a custodial parent and one or more children, or a child or children in foster care placement. The family is sometimes called the assistance unit. **Cambodian –** បុគ្គលណាម្នាក់ ឬច្រើននាក់ដែលប្រាក់ឧបត្ថម្ភត្រូវបានស្នើសុំតាងនាមឲខ្លួនពួកគេ ដែលរួមបញ្ចូលទាំងឪពុក/ម្ដាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ ហើយមានកូនម្នាក់ ឬ ច្រើននាក់ត្រូវបានដាក់បញ្ចូលទៅក្នុងការចិញ្ចឹមថែទាំ។ គ្រួសារ នៅពេលខ្លះ ត្រូវបានហៅថាជាអង្គភាពជំនួយ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Family Independence Program** *n.* | FIP | កម្មវិធីភាពឯករាជ្យរបស់គ្រួសារ | An experimental Washington state public assistance program (1988-1993) that paid cash incentives for participation in education, training or work. **Cambodian –** កម្មវិធីជំនួយសាធារណៈរបស់រដ្ឋវ៉ាស៊ីនតោនដែលមានការពិសោធន៍ **(1988-1993)** ថាប្រាក់លើកទឹកចិត្តត្រូវបានទូទាត់ជាសាច់ប្រាក់សម្រាប់ការចូលរួមនៅក្នុងការអប់រំ ការបណ្តុះបណ្តាល ឬការធ្វើការ។ |
| **Family Law Facilitator** *n.* | | អ្នកជួយសម្រួលច្បាប់គ្រួសារ | A staff person in a county clerk's office who distributes forms and information about court processes like modifying a court order, filing for divorce and filing a parenting plan. **Cambodian –** បុគ្គលិកណាម្នាក់នៅក្នុងការិយាល័យរបស់ក្រឡាបញ្ជីនៅក្នុងខោនធីដែលចែកចាយ ទម្រង់បែបបទ និងព័ត៌មានស្តីពីដំណើរការនានារបស់តុលាការ ដូចជាការកែប្រែ ដីកាតុលាការ ការដាក់ពាក្យស្នើសុំលែងលះ និងការដាក់ពាក្យស្នើសុំផែនការរបស់ឪពុកម្តាយ។ |
| **Family Member** *n.* | | សមាជិកគ្រួសារ | The caretaker relative, the child(ren) and any other person whose needs are considered in determining eligibility for assistance. **Cambodian –** សាច់ញាតិដែលជាអ្នកថែទាំកុមារម្នាក់ (ច្រើននាក់) និងបុគ្គលណាម្នាក់ផ្សេងទៀត ដែលតម្រូវការរបស់ពួកគេត្រូវបានយកមកពិចារណានៅក្នុងការកំណត់អំពីសិទ្ធិទទួលបានជំនួយ។ |
| **Family Support Act of 1988** *n.* | | ច្បាប់ទ្រទ្រង់គ្រួសារ | A federal act, revised in 1989, dealing with child support enforcement. **Cambodian –** ច្បាប់សហព័ន្ធ ដែលត្រូវបានកែសម្រួលឡើងវិញនៅក្នុងឆ្នាំ ១៩៨៩ ដោះស្រាយ ចំពោះការអនុវត្តប្រាក់អាហារូបត្ថម្ភ។ |
| **Federal** *adj.* | FED | សហព័ន្ធ | The central government of the United States. **Cambodian –** រដ្ឋាភិបាលកណ្តាលរបស់សហរដ្ឋអាមេរិក។ |
| **Federal Case Registry** *n.* | FCR | ការិយាល័យចុះបញ្ជីរឿងក្តីសហព័ន្ធ | The FCR provides employer and IV-D case information to the states on their NCPs. **Cambodian – FCR** ផ្តល់ព័ត៌មានអំពីនិយោជក និងរឿងក្តី **IV-D** ទៅកាន់រដ្ឋនានានៅលើ **NDC** របស់ពួកគេ។ |
| **Field Office** *n.* | FO | ការិយាល័យតាមផ្នែក | A Division of Child Support office. **Cambodian –** ការិយាល័យផ្នែកប្រាក់អាហារូបត្ថម្ភ។ |
| **Filed** *v.* | | ផ្នែក | To enter legal documents on public official records. **Cambodian –** បញ្ចូលឯកសារច្បាប់នៅលើកំណត់ត្រាផ្លូវការសាធារណៈ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Final Court order** *n.* | | ដីកាតុលាការស្ថាពរ | An order that settles issues such as child support, custody, paternity and property distribution and specific court actions. **Cambodian –** ដីកាដែលដោះស្រាយបញ្ហានានា ដូចជាប្រាក់អាហារូបត្ថម្ភ សិទ្ធិចិញ្ចឹមបីបាច់ បិតុភាព និងការបែងចែកទ្រព្យសម្បត្តិ និងចំណាត់ការតុលាការជាក់លាក់នានា។ |
| **Findings of Fact** *n.* | FFCL | លទ្ធផលនៃការពិត | The conclusion or decision reached in a case at law, by evidence, as distinguished from interpretation of law. **Cambodian –** សេចក្តីសន្និដ្ឋាន ឬសេចក្តីសម្រេចដែលបានឈានដល់នៅក្នុងរឿងក្តីណាមួយតាមផ្លូវច្បាប់ តាមរយៈភ័ស្តុតាង ខុសពីការបកស្រាយរបស់ច្បាប់។ |
| **Food Stamps** *n.* | FS | ត្រាស្បៀងអាហារ | The DSHS IV-A program responsible for administering the federal United States Department of Agriculture food to families in need. See Basic Food Assistance. **Cambodian –** កម្មវិធី **DSHS IV-A** ទទួលខុសត្រូវចំពោះការគ្រប់គ្រងស្បៀងអាហាររបស់ក្រសួង កសិកម្មនៃសហព័ន្ធសហរដ្ឋអាមេរិកសម្រាប់ក្រុមគ្រួសារដែលមានការខ្វះខាត។ ចូរមើលជំនួយស្បៀងអាហារកម្រិតមូលដ្ឋាន។ |
| **Foreign order** *n.* | | ដីកាក្រៅប្រទេស | Any order issued by a jurisdiction other than a state of the United States (Indian Tribe, District of Columbia and Puerto Rico, U.S. Virgin Islands). **Cambodian –** ដីកាណាមួយដែលត្រូវបានចេញដោយយុត្តាធិការណាមួយដែលមិនមែនជារដ្ឋណាមួយរបស់សហរដ្ឋអាមេរិកនោះទេ (កុលសម្ព័ន្ធឥណ្ឌាស្រុកកូឡុំប៊ី និងពៃតូរីកូ កោះវឺជីននៃសហរដ្ឋអាមេរិក)។ |
| **Foster Care** *n.* | FC | កម្មវិធីចិញ្ចឹមថែទាំ | The placement of children in homes under the care of adults who are not their natural parents. **Cambodian –** ការទុកកុមារឲនៅក្នុងផ្ទះក្រោមការថែទាំរបស់អ្នកដែលមិនមែនជាឪពុកម្តាយតាមធម្មជាតិរបស់ពួកគេ។ |
| **Foster Care Program IV-E,** *n.* | 4E | កម្មវិធីចិញ្ចឹមថែទាំ IV-E | The Washington state program administered by DSHS Children's Administration. **Cambodian –** កម្មវិធីរបស់រដ្ឋវ៉ាស៊ីនតោនត្រូវបានគ្រប់គ្រងដោយរដ្ឋបាលកុមារ **DSHS**។ |
| **Fraud** *n.* | | ការក្លែងបន្លំ | The misrepresentation of the existence or the non-existence of a fact. **Cambodian –** ការធ្វើឲមានការយល់ខុសចំពោះអត្ថិភាព ឬការគ្មានអត្ថិភាពនៃការពិតណាមួយ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Full credit profile report** *n.* | | របាយការណ៍ស្តីពីប្រវត្តិឥណទានពេញលេញ | A listing by the credit bureau of an individual's current name and address, employer, credit and trade lines, public record information and previous inquiries. **Cambodian –** ការរៀបរាប់ដោយការិយាល័យឥណទានអំពីឈ្មោះ និងអាសយដ្ឋានបច្ចុប្បន្ន និយោជក ឥណទាន និងបណ្តាញពាណិជ្ជកម្ម ព័ត៌មានស្តីពីកំណត់ត្រាសាធារណៈ និងសំណួរមុនៗ របស់បុគ្គលណាម្នាក់។ |
| **Full support enforcement services** *n.* | | សេវាអនុវត្តប្រាក់ឧបត្ថម្ភពេញលេញ | The services available in a Title IV-D case, including the establishment of child support orders, paternity establishment, enforcement of child support and spousal support orders, establishment and enforcement of medical support, modificaton of support orders and distribution of child support and spousal support payments. **Cambodian –** សេវានានាដែលអាចរកបាននៅក្នុងចំណងជើងរឿងក្តី **IV-D** ដែលរួមបញ្ចូលទាំង ការបង្កើតដីកាប្រាក់អាហារូបត្ថម្ភ, ការបង្កើតបិតុភាព, ការអនុវត្តដីកា ប្រាក់អាហារូបត្ថម្ភ និងប្រាក់ឧបត្ថម្ភស្វាមី/ភរិយា, ការបង្កើត និងការអនុវត្ត ប្រាក់ឧបត្ថម្ភផ្នែកវេជ្ជសាស្ត្រ, ការកែប្រែដីកាប្រាក់ឧបត្ថម្ភ និងការបែងចែងការទូទាត់ ប្រាក់អាហារូបត្ថម្ភ និង ប្រាក់ឧបត្ថម្ភស្វាមី/ភរិយា។ |
| **Garnishment** *n.* | | អំណូសឃាត់ | A Washington state superior court order for seizing wages to pay a debt. **Cambodian –** ដីការបស់តុលាការកំពូលនៃរដ្ឋវ៉ាស៊ីនតោន សម្រាប់រឹបអូសប្រាក់ឈ្នួលដើម្បីទូទាត់បំណុល។ |
| **General Assistance** *n.* | GA | ជំនួយទូទៅ | Programs that pay a cash grant including Aged, Blind or Disabled (ABD) or Pregnant Women's Assistance (PWA) and programs that provide non-cash assistance such as a referral for Housing and Emergent Needs (HEN). **Cambodian –** កម្មវិធីដែលទូទាត់ជំនួយជាសាច់ប្រាក់ ដែលរួមបញ្ចូលទាំងជំនួយដល់មនុស្សចាស់ ជនពិការភ្នែក ឬជនពិការ **(ABD)** ឬជំនួយរបស់ស្ត្រីមានផ្ទៃពោះ **(PWA)** និង កម្មវិធីនានាដែលផ្តល់ជំនួយដែលមិនមែនជាសាច់ប្រាក់ ដូចជាការយោងដល់តម្រូវការផ្នែកទីលំនៅ និងតម្រូវការនៅគ្រាអាសន្ន **(HEN)** ជាដើម។ |
| **Genetic Test** *n.* | | ការធ្វើតេស្តសេនេទិច | An analysis of genetic markers only to exclude or identify a man as the father or a woman as the mother of a child. **Cambodian –** ការវិភាគអំពីគំនូសសម្គាល់នៃហ្សែនត្រូវបានធ្វើឡើងដើម្បីតែការដកចេញ ឬសម្គាល់ បុរសម្នាក់ថាជាឪពុក ឬស្ត្រីម្នាក់ថាជាម្តាយរបស់កុមារម្នាក់តែប៉ុណ្ណោះ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Good Cause**<br>*n.* | GC | ដើមហេតុល្អ | A CSO determination, based upon potential harm to the CP or children that the CP does not have to cooperate with DCS. **Cambodian –** ការកំណត់របស់ **CSO** ដោយផ្អែកលើសេចក្ដីអន្តរាយជាសក្ដានុពលចំពោះ **CP** និងកុមារដែល **CP** មិនបានសហការណ៍ជាមួយ **DCS**។ |
| **Good Cause for a late hearing**<br>*n.* | | ដើមហេតុល្អសម្រាប់ការបើកសវនាការយឺតយ៉ាវ | The circumstances that make it difficult to respond with specific time frames to any DCS notice or action giving hearing rights. **Cambodian –** កាលៈទេសៈដែលធ្វើឲមានការលំបាកក្នុងការឆ្លើយតបនៅក្នុងចន្លោះពេលជាក់លាក់ ទៅកាន់សេចក្ដីជូនដំណឹង ឬចំណាត់ការក្នុងការផ្ដល់សិទ្ធិបើកសវនាការរបស់ **DCS**។ |
| **Government**<br>*n.* | GOVT | រដ្ឋាភិបាល | The political administration and control of public policy. **Cambodian –** រដ្ឋបាលនយោបាយ និងការគ្រប់គ្រងរបស់គោលនយោបាយសាធារណៈ។ |
| **Grace period**<br>*n.* | | រយៈពេលអនុគ្រោះ | A specified time period in a court or administrative order after the due date and before collection action is taken. **Cambodian –** ថិរវេលាដែលបានបញ្ជាក់នៅក្នុងដីកាតុលាការ ឬដីកាផ្នែករដ្ឋបាលក្រោយកាលបរិច្ឆេទដល់កំណត់បង់ និងមុនពេលដែលចំណាត់ការក្នុងការប្រមូលប្រាក់ណាមួយត្រូវបានធ្វើឡើង។ |
| **Head of Household**<br>*n.* | | មេគ្រួសារ | The parent or parents in a child's home. **Cambodian –** ឪពុក/ម្ដាយ ឬឪពុកម្ដាយនៅក្នុងផ្ទះរបស់កុមារណាម្នាក់។ |
| **Headquarters**<br>*n.* | HQ | ទីស្នាក់ការ | An administration or operations center. **Cambodian –** មជ្ឈមណ្ឌលរដ្ឋបាល ឬមជ្ឈមណ្ឌលដំណើរការនានា។ |
| **Health care costs**<br>*n.* | | សោហ៊ុយលើការថែទាំសុខភាព | The medical, dental and optometric expenses established in the support obligations or stated as a fixed dollar amount by a child support order. **Cambodian –** ចំណាយផ្នែកវេជ្ជសាស្ត្រ ចំណាយផ្នែកទន្តសាស្ត្រ និងចំណាយផ្នែកចក្ខុសាស្ត្រដែលត្រូវបានបង្កើតឡើងនៅក្នុងកាតព្វកិច្ចប្រាក់ឧបត្ថម្ភ ឬដែលត្រូវបានបញ្ជាក់ជាចំនួនប្រាក់ដុល្លារថេរដោយដីកាប្រាក់អាហារូបត្ថម្ភណាមួយ។ |
| **Health insurance**<br>*n.* | | ធានារ៉ាប់រងសុខភាព | Insurance coverage for all medical services related to a person's general health and well-being. **Cambodian –** ការគ្របដណ្ដប់ផ្នែកធានារ៉ាប់រងសម្រាប់សេវាផ្នែកវេជ្ជសាស្ត្រទាំងអស់ដែលពាក់ព័ន្ធនឹងសុខភាព និងសុខមាលភាពទូទៅរបស់មនុស្សម្នាក់។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Hearing**<br>*n.* | HRG | សវនាការ | A proceeding before an Administrative Law Judge at the Office of Administrative Hearings (OAH) that gives a party an opportunity to be heard in disputes about a DSHS program. **Cambodian –** ការដំណើរការរឿងក្តីនៅចំពោះមុខចៅក្រមនៃច្បាប់រដ្ឋបាលនៅការិយាល័យ សវនាការរដ្ឋបាល **(OAH)** ដែលផ្តល់ជូនភាគីម្ខាងនូវឱកាសក្នុងការទទួលបានការបើកសវនាការនៅក្នុងវិវាទនានាស្តីពីកម្មវិធីណាមួយរបស់ **DSHS**។ |
| **Home state**<br>*n.* | | រដ្ឋកំណើត | The state a child lived in with a parent for at least six consecutive months immediately before the time of filing of a petition for child support. **Cambodian –** ការថែងថាកុមារបានរស់នៅជាមួយឪពុក/ម្តាយក្នុងរយ:ពេលយ៉ាងតិចប្រាំមួយខែ ជាប់ៗគ្នាមុនពេលដាក់ពាក្យស្នើសុំប្រាក់អាហារូបត្ថម្ភ។ |
| **Household**<br>*n.* | HH | គ្រួសារ | A place and the members of a family and others who live under the same roof. **Cambodian –** ទីកន្លែង និងសមាជិកគ្រួសារ និងអ្នកដទៃទៀតដែលរស់នៅក្រោមដំបូលតែមួយ។ |
| **Husband**<br>*n.* | HUSB | ស្វាមី | A married man. **Cambodian –** បុរសដែលរៀបអាពាហ៍ពិពាហ៍រួចហើយ |
| **Immediate Wage Withholding**<br>*n.* | IWW | ការកាត់ទុកប្រាក់ឈ្នួលភ្លាមៗ | A requirement of the federal Family Support Act that state IV-D agencies take wage withholding actions immediately after a child support order is issued. **Cambodian –** លក្ខខណ្ឌតម្រូវរបស់ច្បាប់គាំទ្រគ្រួសាររបស់សហព័ន្ធដែលថែងថា ទីភ្នាក់ងារ **IV-D** អនុវត្តចំណាត់ការកាត់ទុកប្រាក់ឈ្នួលភ្លាមៗបន្ទាប់ពីដីកាប្រាក់អាហារូបត្ថម្ភត្រូវបានចេញ។ |
| **Immediate Wage Withholding Order**<br>*n.* | | ដីកាកាត់ទុកប្រាក់ឈ្នួលភ្លាមៗ | A support order entered on or after July 1, 1990 that has automatic notice and enforcement language that says wage or income withholding may be taken at any time after the entry of the order. **Cambodian –** ដីកាប្រាក់ឧបត្ថម្ភត្រូវបានចុះនៅឬក្រោយថ្ងៃទី **1** ខែកក្កដា ឆ្នាំ **1990** ដែលមានសេចក្តីជូនដំណឹងជាស្វ័យប្រវត្តិ និងភាសានៃការអនុវត្តដែលនិយាយថា ការកាត់ទុកប្រាក់ឈ្នួល ឬប្រាក់ចំណូលអាចត្រូវបានធ្វើឡើងនៅពេលណាមួយ ក្រោយពេលចូលជាធរមាននៃដីកានោះ។ |
| **Include, Including, Inclusive**<br>*v.* | INCL | រួមបញ្ចូល | To add or put into a class, group or total. **Cambodian –** បន្ថែម ឬដាក់ចូលទៅតាមកម្រិត ក្រុម ឬចំនួនសរុប។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Income**<br>*n.* | | ប្រាក់ចំណូល | Earnings or other periodic payments of money from any source and any other property subject to withholding for child support under law. **Cambodian –** ប្រាក់ចំណូល ឬការទូទាត់ប្រាក់ទៀងទាត់ផ្សេងទៀតពីប្រភពណាមួយ និងទ្រព្យសម្បត្តិណាមួយផ្សេងទៀតដែលត្រូវកាត់ទុកសម្រាប់ប្រាក់អាហារូបត្ថម្ភយោងតាមច្បាប់។ |
| **Income withholding action**<br>*n.* | | ចំណាត់ការកាត់ទុកប្រាក់ចំណូល | All withholding actions DCS is authorized to take. **Cambodian –** រាល់ចំណាត់ការក្នុងការកាត់ទុកទាំងអស់របស់ **DCS** ត្រូវបានអនុញ្ញាតឲធ្វើឡើង។ |
| **Income withholding order**<br>*n.* | | ដីកាកាត់ទុកប្រាក់ចំណូល | An order sent to an employer to take child support money from the earnings of an NCP. **Cambodian –** ដីកាមួយច្បាប់ត្រូវបានបញ្ជូនទៅកាន់និយោជកដើម្បីកាត់ប្រាក់អាហារូបត្ថម្ភពីប្រាក់ចំណូលរបស់ **NCP** ណាម្នាក់។ |
| **Information**<br>*n.* | INFO | ព័តិមាន | Facts and knowledge shared as instruction  or experience. **Cambodian –** ការពិត និងចំណេះដឹងត្រូវបានចែករំលែកជាការណែនាំ ឬបទពិសោធន៍។ |
| **Initial Order**<br>*n.* | INIT | ដីកាដំបូង | A hearing decision made by an ALJ that may be reviewed by a DSHS Board of Appeals review judge. **Cambodian –** សេចក្តីសម្រេចនៃសវនាការមួយត្រូវបានធ្វើឡើងដោយ **ALJ** ដែលអាចត្រូវបានត្រួតពិនិត្យឡើងវិញដោយចៅក្រមត្រួតពិនិត្យឡើងវិញនៃក្រុមប្រឹក្សាបណ្តឹងឧទ្ធរណ៍របស់ **DSHS**។ |
| **Initiating Jurisdiction**<br>*n.* | IJ | យុត្តាធិការផ្តួចផ្តើម | Also called Initiating State. In an interstate case, the state or jurisdiction that requests enforcement or establishment of a child support obligation by the state where the NCP lives or has assets. **Cambodian –** ត្រូវបានហៅផងដែរថាជារដ្ឋផ្តួចផ្តើម។ នៅក្នុងរឿងក្តីអន្តររដ្ឋ រដ្ឋ ឬយុត្តាធិការដែលស្នើសុំការអនុវត្តច្បាប់ ឬបង្កើតកាតព្វកិច្ចប្រាក់អាហារូបត្ថម្ភដោយរដ្ឋដែល **NCP** រស់នៅ ឬមានទ្រព្យសកម្មនៅទីនោះ។ |
| **Initiating State**<br>*n.* | IS | រដ្ឋផ្តួចផ្តើម | An initiating jurisdiction. **Cambodian –** យុត្តាធិការផ្តួចផ្តើម។ |
| **Insurance**<br>*n.* | INS | ការធានារ៉ាប់រង | The medical, dental and optometrical coverage provided by an insurer. **Cambodian –** ការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងចក្ខុសាស្ត្រត្រូវបានផ្តល់ជូនដោយអ្នកផ្តល់ធានារ៉ាប់រង។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Insurer**<br>*n.* | | អ្នកធានារ៉ាប់រង | A company providing disability, health care services, health care coverage, a health maintenance organization or an employer or union providing health insurance coverage on a self-insured basis. **Cambodian –** ក្រុមហ៊ុនមួយផ្តល់ធានារ៉ាប់រងលើពិការភាព សេវាថែទាំសុខភាពទានាការថែទាំសុខភាព អង្គការថែទាំសុខភាព ឬនិយោជក ឬសហជីពផ្តល់ការធានារ៉ាប់រងសុខភាពតាមមូលដ្ឋាននៃអ្នកទទួលបានការធានារ៉ាប់រងរបស់ខ្លួន។ |
| **Internal Revenue Service**<br>*n.* | IRS | សេវាប្រាក់ចំណូលផ្ទៃក្នុង | A federal agency whose duties include collecting income tax. **Cambodian –** ទីភ្នាក់ងាររបស់សហព័ន្ធដែលមានភារកិច្ចរួមបញ្ចូលទាំងការប្រមូលពន្ធលើប្រាក់ចំណូលផងដែរ។ |
| **Intergovern-mental Wage Withholding**<br>*v.* | ISW | ការកាត់ទុកប្រាក់ឈ្នួលអន្តររដ្ឋាភិបាល | A process allowed under federal law that allows the establishment or enforcement of child support orders between states. **Cambodian –** ដំណើរការមួយដែលត្រូវបានអនុញ្ញាតយោងតាមច្បាប់របស់សហព័ន្ធ ដែលអនុញ្ញាតឲមានការបង្កើត ឬការអនុវត្តដីកាប្រាក់អាហារូបត្ថម្ភទាទារវាងរដ្ឋនានា។ |
| **IRS certification**<br>*n.* | | ការបញ្ជាក់ IRS | The formal documentation by the federal office of the Internal Revenue Service that identifies a person's income tax return for child support withholding action. **Cambodian –** សំណុំឯកសារផ្លូវការរបស់ការិយាល័យសេវាប្រាក់ចំណូលផ្ទៃក្នុងរបស់សហព័ន្ធដែលសម្គាល់ផលរបរនៃប្រាក់ចំណូលរបស់មនុស្សម្នាក់សម្រាប់ចំណាត់ការកាត់ទុកប្រាក់អាហារូបត្ថម្ភ។ |
| **IRS intercept**<br>*n.* | | ការថតទុករបស់ IRS | Seizure of an NCP's federal income tax refund. **Cambodian –** ការដកហូតយកការប្រគល់ជូនវិញនូវពន្ធលើប្រាក់ចំណូលរបស់សហព័ន្ធរបស់ **NCP** ណាម្នាក់។ |
| **IRS offset**<br>*adv.* | | ការកាត់កង IRS | Internal Revenue Service action that reduces an NCP's federal income tax refund by the amount of a child support arrears debt. **Cambodian –** ចំណាត់ការរបស់សេវាប្រាក់ចំណូលផ្ទៃក្នុងដែលកាត់បន្ថយការប្រគល់ជូនវិញនូវពន្ធលើប្រាក់ចំណូលរបស់សហព័ន្ធរបស់ **NCP** ណាម្នាក់តាមចំនួនបំណុលទូទាត់តាមក្រោយនៃប្រាក់អាហារូបត្ថម្ភ។ |
| **Issuing state**<br>*n.* | | រដ្ឋដែលចេញ | The state a court issues a support order or makes a judgment determining parentage. **Cambodian –** រដ្ឋដែលតុលាការមួយចេញដីកាប្រាក់ឧបត្ថម្ភ ឬធ្វើសេចក្តីវិនិច្ឆ័យកំណត់អំពីភាពជាឪពុកម្តាយ។ |

## Division of Child Support

# English-language Learner Glossary

### English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **IV-A, 4A**<br>*n.* | IV-A | IV-A | IV-A number - The number assigned by the CSO (Community Service Office) to a public assistance case. **Cambodian –** លេខ **IV-A** -លេខដែលត្រូវបានកំណត់ដោយ **CSO** (ការិយាល័យសេវាសហគមន៍) ចំពោះរឿងក្តីជំនួយសាធារណៈណាមួយ។ |
| **IV-D, 4D**<br>*n.* | IV-D | IV-D | IV-D (pronounced "four-D") - The title (section) of the Social Security Act that contains laws regarding child support enforcement and collection. **Cambodian – IV-D** (បញ្ចេញសម្លេងថា "បួន-**D**"-ចំណងជើង (ផ្នែក) នៃច្បាប់សន្តិសុខសង្គម ដែលមានច្បាប់នានាដែលពាក់ព័ន្ធនឹងការអនុវត្ត និងការប្រមូលប្រាក់អាហារូបត្ថម្ភ។ |
| **IV-E, 4E**<br>*n.* | IV-E | IV-E | IV-E (pronounced "four-E") - The title (section) of the Social Security Act that contains the laws for the federally funded foster care program. **Cambodian – IV-E** (បញ្ចេញសម្លេងថា "បួន-**E**"-ចំណងជើង (ផ្នែក) នៃច្បាប់សន្តិសុខសង្គម ដែលមានច្បាប់នានាសម្រាប់កម្មវិធីចិញ្ចឹមថែទាំដែលទទួលបានមូលនិធិពីសហព័ន្ធ។ |
| **Judgment**<br>*n.* | JGMT | សាលក្រម | A court order to pay a certain sum established by the court for costs, fees, etc. **Cambodian –** ដីកាតុលាការបង្គាប់ឲទូទាត់ប្រាក់ក្នុងចំនួនជាក់លាក់ដែលត្រូវបានបង្កើតឡើងដោយតុលាការសម្រាប់សោហ៊ុយប្រាក់កម្រៃនានា។ល។ |
| **Judgment lien**<br>*n.* | | សិទ្ធិឃាត់ទុករបស់សាលក្រម | A lien created by the entry of a court-ordered sum by certain judgment. **Cambodian –** សិទ្ធឃាត់ទុកមួយត្រូវបានបង្កើតឡើងដោយការបញ្ចូលទឹកប្រាក់ក្នុងចំនួនណាមួយ ដែលតុលាការបានបង្គាប់ដោយសាលក្រមជាក់លាក់។ |
| **Jurisdiction**<br>*n.* | JURIS | យុត្តាធិការ | The authority of a court, agency or government to decide a case or legal issue, or to take action against a person or a person's assets. **Cambodian –** សិទ្ធិអំណាចរបស់តុលាការ ទីភ្នាក់ងារ ឬរដ្ឋាភិបាលក្នុងការសម្រេចចិត្តលើរឿងក្តី ឬបញ្ហាតាមផ្លូវច្បាប់ណាមួយ ឬអនុវត្តចំណាត់ការប្រឆាំងនឹងមនុស្សម្នាក់ ឬទ្រព្យសកម្មរបស់មនុស្សម្នាក់។ |
| **Juvenile**<br>*n.* | JUV | អនីតិជន | A child 18 years and younger.<br>**Cambodian –** កុមារដែលមានអាយុ **18** ឆ្នាំ និងតិចជាងនេះ។ |
| **Juvenile Rehabilitation**<br>*n.* | JR | ការស្តារនីតិសម្បទាអនីតិជន | Serves Washington state's highest-risk youth. Youth are committed to Juvenile Rehabilitation custody through county juvenile courts. **Cambodian –** ផ្តល់សេវាដល់យុវជនដែលប្រឈមនឹងហានិភ័យខ្ពស់បំផុតរបស់រដ្ឋវ៉ាស៊ីនតោន។ យុវជនប្តេជ្ញាចិត្តទទួលយកការឃុំឃាំងសម្រាប់នីតិសម្បទារបស់អនីតិជនតាមរយៈ តុលាការអនីតិជនរបស់ខោនធី។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Labor and Industries**<br>*n.* | L&I | ពលកម្ម និងឧស្សាហកម្ម | The Washington state agency that administers workers compensation benefits and injury claims. **Cambodian –** ទីភ្នាក់ងាររបស់រដ្ឋវ៉ាស៊ីនតោនដែលគ្រប់គ្រងផលប្រយោជន៍នៃសំណងរបស់កម្មករ និងការទាមទារសំណងលើការរងរបួស។ |
| **Language**<br>*n.* | LANG | ភាសា | The wording of a legal document or statute. **Cambodian –** ពាក្យនៅក្នុងឯកសារច្បាប់ ឬនៅក្នុងច្បាប់។ |
| **Law**<br>*n.* | | ច្បាប់ | A rule or a system of rules established by authority, society or custom. **Cambodian –** វិធាន ឬប្រព័ន្ធនៃវិធានមួយដែលត្រូវបានបង្កើតឡើងដោយអាជ្ញាធរ សង្គម ឬទំនៀមទម្លាប់។ |
| **License**<br>*n.* | LIC | អាជ្ញាប័ណ្ណ | Official or legal permission to do or own a specified thing, like drive a car or do a specific job. **Cambodian –** ការអនុញ្ញាតជាផ្លូវការ ឬតាមផ្លូវច្បាប់ធ្វើ ឬកាន់កាប់វត្ថុដែលបានបញ្ជាក់ណាមួយ ដូចជាការបើកបររថយន្ត ឬធ្វើការងារជាក់លាក់ណាមួយជាដើម។ |
| **License Suspension**<br>*n.* | | ការផ្អាកអាជ្ញាប័ណ្ណ | The act of denying a person a driver's license to drive a vehicle, hunt for game or fish. **Cambodian –** សកម្មភាពក្នុងការបដិសេធចំពោះអាជ្ញាប័ណ្ណបើកបររបស់មនុស្សម្នាក់មិនឲបើកបរយានជំនិះណាមួយ មិនឲធ្វើការបរបាញ់ជាល្បែង ឬការនេសាទត្រី។ |
| **Limited English Speaking**<br>*n.* | LES | ការនិយាយភាសាអង់គ្លេសនៅមានកម្រិត | This refers to persons who do not or have little knowledge and usage of the English language. **Cambodian –** នេះសំដៅលើមនុស្សទាំងឡាយដែលគ្មាន ឬមានចំណេះដឹង និងការប្រើប្រាស់ភាសាអង់គ្លេសបានតិចតួច។ |
| **Locate, Located, Location**<br>*v.* | LOC | ការកំណត់ទីតាំង, មានទីតាំងស្ថិតនៅ, ទីតាំង | Efforts to find an NCP to serve a notice or collect child support. **Cambodian –** កម្លាំងក្នុងការស្វែងរក **NCP** ណាម្នាក់ដើម្បីផ្តល់សេចក្តីជូនដំណឹង ឬប្រមូលប្រាក់អាហារូបត្ថម្ភ។ |
| **Long-arm Statute**<br>*n.* | | លក្ខន្តិកៈឆ្លងរដ្ឋ | State law allows the authority to collect child support from a person living in another state. **Cambodian –** ច្បាប់រដ្ឋអនុញ្ញាតឲអាជ្ញាធរប្រមូលប្រាក់អាហារូបត្ថម្ភពីមនុស្សម្នាក់ដែលរស់នៅក្នុងរដ្ឋណាមួយផ្សេងទៀត។ |
| **Medical Assistance Only**<br>*n.* | MAO | ជំនួយផ្នែកវេជ្ជសាស្ត្រតែប៉ុណ្ណោះ | A DCS phrase for cases when the custodial parent receives Medicaid (medical assistance) but does not receive public assistance money. **Cambodian – DCS** បញ្ចេញមតិចំពោះរឿងក្តីនានានៅពេលដែលឪពុក/ម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់ទទួលបាន **Medicaid** (ជំនួយផ្នែកវេជ្ជសាស្ត្រ) ប៉ុន្តែមិនទទួលបានប្រាក់ជំនួយសាធារណៈនោះទេ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Medical Child Support Order** *n.* | MCSO | ដីកាប្រាក់អាហារូបត្ថម្ភផ្នែកវេជ្ជសាស្ត្រ | A court order issued by a jurisdiction or administrative agency that provides medical support for a child. **Cambodian –** ដីកាតុលាការដែលត្រូវបានចេញដោយយុត្តាធិការ ឬទីភ្នាក់ងាររដ្ឋបាលណាមួយ ដែលផ្តល់ប្រាក់ឧបត្ថម្ភផ្នែកវេជ្ជសាស្ត្រសម្រាប់កុមារណាម្នាក់។ |
| **Medical Enforcement Only** *n.* | MEO | ការអនុវត្តផ្នែកវេជ្ជសាស្ត្រតែប៉ុណ្ណោះ | Refers to cases where DCS only enforces health insurance for custodial parents. **Cambodian –** សំដៅដល់រឿងក្តីនានាដែល **DCS** ធ្វើការអនុវត្តតែការធានារ៉ាប់រងផ្នែកសុខភាព សម្រាប់ឪពុកម្តាយដែលមានសិទ្ធិចិញ្ចឹមបីបាច់តែប៉ុណ្ណោះ។ |
| **Medical Support** *n.* | MED | ប្រាក់ឧបត្ថម្ភផ្នែកវេជ្ជសាស្ត្រ | The court ordered fixed dollar amount for health care costs or health insurance coverage for a child. **Cambodian –** តុលាការបានបង្គាប់ចំនួនប្រាក់ដុល្លារថេរសម្រាប់សោហ៊ុយលើការថែទាំសុខភាព ឬការធានារ៉ាប់រងផ្នែកសុខភាពសម្រាប់កុមារណាម្នាក់។ |
| **Minus, less** *v.* | - | ដក | A deduction…4 minus 2 or (4-2) or stating a smaller amount (it is less than…). **Cambodian –** ការកាត់យក **…4** ដក **2** ឬ **(4-2)** ឬចែងអំពីចំនួនដែលតិចជាងនេះ (តិចជាង**…)**។ |
| **Modification Conference** *n.* | | សន្និបាតស្តីពីការកែប្រែ | An informal meeting where people with child support cases meet with a DCS attorney called a Claims Officer to talk about changing the amount of child support paid. **Cambodian –** ការប្រជុំមិនផ្លូវការមួយដែលបុគ្គលទាំងឡាយនៃរឿងក្តីប្រាក់អាហារូបត្ថម្ភជួបជាមួយមេធាវីរបស់ **DCS** និងបានហៅមន្ត្រីផ្នែកទាមទារណាម្នាក់មកជជែកគ្នាអំពីការកែប្រែចំនួនប្រាក់អាហារូបត្ថម្ភដែលបានទូទាត់។ |
| **Modification, Modified** *n.* | MOD | ការកែប្រែ, បានកែប្រែ | To change or make different from the original. **Cambodian –** កែប្រែ ឬធ្វើឲខុសពីចំនួនដើម។ |
| **Modification review** *n.* | | ការត្រួតពិនិត្យអំពីការកែប្រែ | Refers to a Support Enforcement Officers (SEO) evaluation of DCS records and a CP's or NCP's earnings and other information used to change child support and medical support. **Cambodian –** យោងដល់មន្ត្រីអនុវត្តប្រាក់ឧបត្ថម្ភ **(SEO)** ណាម្នាក់សម្រាប់ការវាយតម្លៃអំពីកំណត់ត្រារបស់ **DCS** និងប្រាក់ចំណូលរបស់ **CP** ឬ **NCP** ណាម្នាក់ និងព័ត៌មានផ្សេងទៀតដែលត្រូវបានប្រើប្រាស់ដើម្បីកែប្រែប្រាក់អាហារូបត្ថម្ភ និងប្រាក់ឧបត្ថម្ភផ្នែកវេជ្ជសាស្ត្រ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Month By Month** *n.* | MXM | មួយខែម្តង | A phrase used to describe a debt calculation that shows payments and nonpayment every month from the beginning of an order to pay child support. **Cambodian –** ពាក្យមួយឃ្លាដែលត្រូវបានប្រើប្រាស់ដើម្បីពណ៌នាអំពីការគណនាបំណុលដែលបង្ហាញអំពីការទូទាត់ និងការមិនទូទាត់ប្រាក់ជារៀងរាល់ខែចាប់ពីពេលចាប់ផ្តើមមានដីកាឲទូទាត់ប្រាក់អាហារូបត្ថម្ភ។ |
| **Monthly Arrears Payment** *n.* | MAP | ការទូទាត់ប្រាក់តាមក្រោយប្រចាំខែ | The least amount paid each month on an arrears debt. **Cambodian –** ចំនួនទឹកប្រាក់តិចបំផុតដែលបានទូទាត់ជារៀងរាល់ខែសម្រាប់បំណុលដែលទូទាត់តាមក្រោយ។ |
| **Monthly Order Amount** *n.* | MOA | ចំនួនទឹកប្រាក់ដែលបានបង្គាប់ប្រចាំខែ | The total amount ordered of current child support and spousal support. **Cambodian –** ទឹកប្រាក់សរុបដែលត្រូវបានបង្គាប់សម្រាប់ប្រាក់អាហារូបត្ថម្ភ និងប្រាក់ឧបត្ថម្ភស្វាមី/ភរិយាបច្ចុប្បន្ន។ |
| **National Medical Support Notice** *n.* | NMSN | សេចក្តីជូនដំណឹងអំពីប្រាក់ឧបត្ថម្ភផ្នែកវេជ្ជសាស្ត្រកម្រិតជាតិ | A federal form used by DCS to tell an NCP to add children to a medical insurance policy. **Cambodian –** ទម្រង់របស់សហព័ន្ធមួយត្រូវបានប្រើប្រាស់ដោយ **DCS** ដើម្បីប្រាប់ **NCP** ឲបន្ថែមកូនចូលទៅក្នុងប័ណ្ណសន្យាធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រ។ |
| **National Immigration Service** *n.* | NIS | សេវាអន្តោប្រវេសន៍ជាតិ | The federal department that administers immigration to the United States. **Cambodian –** ក្រសួងរបស់សហព័ន្ធដែលគ្រប់គ្រងការធ្វើអន្តោប្រវេសន៍ទៅកាន់សហរដ្ឋអាមេរិក។ |
| **Negotiate** *v.* | NEG | ការចរចា | To talk to resolve a dispute. **Cambodian –** ជជែកគ្នាដើម្បីដោះស្រាយវិវាទណាមួយ។ |
| **Negotiated Settlement** *n.* | | ការដោះស្រាយដែលបានចរចាគ្នា | A mutual agreement between an NCP and a CLO setting a child support debt. **Cambodian –** កិច្ចព្រមព្រៀងទៅវិញទៅមករវាង **NCP** និង **CLO** ដែលកំណត់បំណុលនៃប្រាក់អាហារូបត្ថម្ភ។ |
| **Net Income** *n.* | | ប្រាក់ចំណូលសុទ្ធ | Take home pay also called disposable earnings. The money left after legal deductions are taken from pay. **Cambodian –** ប្រាក់យកទៅផ្ទះវិញក៏ត្រូវបានហៅថាជាប្រាក់ចំណូលក្រោយការកាត់កងផងដែរ។ ប្រាក់ដែលនៅសល់បន្ទាប់ពីមានការកាត់យកតាមផ្លូវច្បាប់ពីការទូទាត់ប្រាក់។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Nonassistance**<br>*n.* | | គ្មានជំនួយ | The term used to identify a child support case when the parties are not receiving public assistance (TANF). **Cambodian –** លក្ខខណ្ឌត្រូវបានប្រើប្រាស់ដើម្បីសម្គាល់រឿងក្តីប្រាក់អាហារូបត្ថម្ភ នៅពេលដែលគូភាគីមិនមែនកំពុងទទួលបានជំនួយផ្នែកសាធារណៈ **(TANF)**។ |
| **Nonassistance Case/Services**<br>*n.* | | រឿងក្តី/សេវាគ្មានជំនួយ | DCS collection services for persons not getting public assistance money. **Cambodian –** សេវាប្រមូលផ្តុំរបស់ **DCS** សម្រាប់ជនដែលមិនកំពុងទទួលបានប្រាក់ជំនួយសាធារណៈ។ |
| **Noncompliance**<br>*v.* | | មិនអនុលោមតាម | An employer or union failure to: answer, send money and enroll children in medical insurance after legal service of a notice. **Cambodian –** និយោជក ឬសហជីពដែលខកខានមិនបាន ៖ ឆ្លើយតប ផ្ញើប្រាក់ និងចុះឈ្មោះកូនចូលក្នុងការធានារ៉ាប់រងផ្នែកសុខភាពបន្ទាប់ពីមានការជូនដំណឹងតាមផ្លូវច្បាប់។ |
| **Noncooperation**<br>*v.* | NON-COOP | គ្មានកិច្ចសហប្រតិបត្តិការ | A description of a CP's status when he or she does not give DCS information needed to enforce child support. **Cambodian –** ការពណ៌នាអំពីស្ថានភាពរបស់ **CP** នៅពេលដែលគាត់ ឬនាងមិនផ្តល់ព័ត៌មាន ដែលចាំបាច់ដើម្បីអនុវត្តប្រាក់អាហារូបត្ថម្ភ។ |
| **Noncourt Ordered**<br>*v.* | NCO | គ្មានដីកាតុលាការ | Payment responsibilities not always listed in a court order like day care. **Cambodian –** ទំនួលខុសត្រូវក្នុងការទូទាត់ប្រាក់មិនមែនតែងតែត្រូវបានរៀបរាប់នៅក្នុងដីកា តុលាការ ដូចជាការថែទាំក្មេងនៅពេលថ្ងៃជាដើមនោះទេ។ |
| **Noncustodial Parent**<br>*n.* | NCP | ឪពុកម្តាយដែលគ្មានសិទ្ធិចិញ្ចឹមបីបាច់ | The parent who does not live in the home with the child and has a responsibility to pay support. NCPs are also referred to as nonresidential parents, noncustodial parents and responsible parents. **Cambodian –** ឪពុក/ម្តាយដែលមិនរស់នៅក្នុងផ្ទះជាមួយកូន និងមានទំនួលខុសត្រូវក្នុងការទូទាត់ប្រាក់ឧបត្ថម្ភ។ **NCPs** ក៏ត្រូវបានសំដៅដល់ឪពុកម្តាយដែលមិនមែនជានិវាសនជនផងដែរ ឪពុកម្តាយដែលគ្មានសិទ្ធិចិញ្ចឹមបីបាច់ និងឪពុកម្តាយដែលមានទំនួលខុសត្រូវផងដែរ។ |
| **Non IV-D case**<br>*n.* | | គ្មានរឿងក្តី IV-D | DCS cases that are not regulated under the Social Security Act: PSO, FCR, Unborn child, Employer Initiated, noncompliance fines and Spousal Support only cases. **Cambodian –** រឿងក្តីរបស់ **DCS** ដែលមិនត្រូវបានធ្វើនិយ័តកម្មយោងតាមច្បាប់សន្តិសុខសង្គម ៖ តែរឿងក្តី **PSO, FCR,** កុមារដែលមិនទាន់កើត, រឿងក្តីដែលផ្តួចផ្តើមដោយនិយោជក, ប្រាក់ពិន័យសម្រាប់ការមិនអនុវត្តតាម និងរឿងក្តីប្រាក់ឧបត្ថម្ភស្វាមី/ភរិយាតែប៉ុណ្ណោះ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Nonresidential Parent** *n.* | | ឪពុកម្តាយដែលមិនមែនជានិវាសនជន | The person not designated as the primary custodian. Referred to as the noncustodial parent. **Cambodian –** បុគ្គលដែលមិនត្រូវបានចាត់តាំងជាអ្នកមានសិទ្ធិចិញ្ចឹមបីបាច់ចម្បង។ ត្រូវបានសំដៅដល់ថាជាឪពុក/ម្តាយដែលគ្មានសិទ្ធិចិញ្ចឹមបីបាច់។ |
| **Nonsufficient Funds** *n.* | NSF | មូលនិធិមិនគ្រប់គ្រាន់ | A banking determination when there is not enough money in a bank account to pay a check written against the account. **Cambodian –** ការកំណត់របស់ធនាគារនៅពេលដែលគ្មានប្រាក់គ្រប់គ្រាន់នៅក្នុងគណនីធនាគារ ដើម្បីទូទាត់មូលប្បទានបត្រដែលត្រូវបានសរសេរប្រឆាំងនឹងគណនីនោះ។ |
| **Nonwage Enforcement Program** *n.* | NWEP | កម្មវិធីអនុវត្តគ្មានប្រាក់ឈ្នួល | A DCS program that locates and seizes an NCP's personal property for nonpayment of child support. **Cambodian –** កម្មវិធី **DCS** ដែលកំណត់ទីតាំង និងដកហូតទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ **NCP** សម្រាប់ការមិនទូទាត់ប្រាក់អាហារូបត្ថម្ភ។ |
| **Not Applicable** *adv.* | N/A | មិនពាក់ព័ន្ធ | A term used when a fact or information does not fit a specific situation. **Cambodian –** លក្ខខណ្ឌត្រូវបានប្រើប្រាស់នៅពេលដែលការពិត ឬព័ត៌មានណាមួយមិនស័ក្តិសមនឹងស្ថានភាពជាក់លាក់ណាមួយ។ |
| **Notice** *n.* | | សេចក្តីជូនដំណឹង | A letter with information that can be legally binding. **Cambodian –** លិខិតមួយច្បាប់រួមជាមួយព័ត៌មានដែលអាចចងកាតព្វកិច្ចតាមផ្លូវច្បាប់។ |
| **Notice and Finding of Parental Responsibility (DSHS 09-710)** *n.* | NFPR | សេចក្តីជូនដំណឹង និងលទ្ធផលស្តីពីទំនួលខុសត្រូវរបស់ឪពុកម្តាយ (DSHS 09-710) | A legally based letter telling a man that he is the father of a child based on DNA testing. **Cambodian –** លិខិតមួយច្បាប់ផ្អែកលើមូលដ្ឋានច្បាប់ដែលប្រាប់បុរសម្នាក់ថាគាត់គឺជាឪពុករបស់កូនម្នាក់ផ្អែកតាមការធ្វើតេស្តឌីអិនអេ។ |
| **Notice and Finding of Financial Responsibility (DSHS 09-275)** *n.* | NFFR | សេចក្តីជូនដំណឹង និងលទ្ធផលស្តីពីទំនួលខុសត្រូវរបស់ឪពុកម្តាយ (DSHS 09-275) | A legally based letter telling a parent that he or she must pay child support. **Cambodian –** លិខិតមួយច្បាប់ផ្អែកលើមូលដ្ឋានច្បាប់ដែលប្រាប់មនុស្សម្នាក់ថា គាត់ ឬនាងត្រូវតែទូទាត់ប្រាក់អាហារូបត្ថម្ភ។ |
| **Notice Of Appearance** *n.* | NOA | សេចក្តីជូនដំណឹងអំពីការបង្ហាញខ្លួន | A formal letter providing information about a hearing or conference board date, time and place. **Cambodian –** លិខិតផ្លូវការមួយច្បាប់ដែលផ្តល់ព័ត៌មានអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការ ឬក្រុមប្រឹក្សាសន្និបាត។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Object, Objection** *v.* | OBJ | ជំទាស់, ការជំទាស់ | To oppose. To express a different opinion or position. **Cambodian –** ប្រឆាំង។ បញ្ចេញគំនិត ឬគោលជំហរខុសគ្នា។ |
| **Office of Administrator for the Courts** *n.* | | ការិយាល័យអ្នករដ្ឋសម្រាប់តុលាការ | The office operates under the direction of the Chief Justice of Washington state supporting the statewide court computer system providing: information, technical support, education, and training for judicial officers, administrators, managers and other court personnel. **Cambodian –** ការិយាល័យដំណើរការយោងតាមការណែនាំរបស់ប្រធានផ្នែកយុត្តិធម៌នៃរដ្ឋវ៉ាស៊ីនតោនដែលគាំទ្រចំពោះប្រព័ន្ធកុំព្យូទ័រតុលាការទូទាំងរដ្ឋ ដែលផ្តល់ ៖ ព័ត៌មាន, ការគាំទ្រផ្នែកបច្ចេកទេស ការអប់រំ និងការបណ្តុះបណ្តាលសម្រាប់មន្ត្រីយុត្តិធម៌ អ្នករដ្ឋបាល អ្នកគ្រប់គ្រង និងបុគ្គលិកតុលាការផ្សេងទៀត។ |
| **Office of Financial Recovery** *n.* | OFR | ការិយាល័យទទួលបានហិរញ្ញវត្ថុមកវិញ | The DSHS program that collects public assistance over-payments. **Cambodian –** កម្មវិធី **DSHS** ដែលប្រមូលប្រាក់ចំណាយហួសប្រមាណលើជំនួយសាធារណៈ។ |
| **Office of Fraud and Accountability** *n.* | OFA | ការិយាល័យក្លែងបន្លំ និងគណនេយ្យភាព | The DSHS program that investigates public assistance fraud. **Cambodian –** កម្មវិធី **DSHS** ដែលស៊ើបអង្កេតការក្លែងបន្លំជំនួយសាធារណៈ។ |
| **Office of Administrative Hearings** *n.* | OAH | ការិយាល័យសវនាការរដ្ឋបាល | This office holds adjudicative proceedings and issues initial decisions, final decisions and orders for DCS. **Cambodian –** ការិយាល័យនេះអនុវត្តដំណើរការរឿងក្តីបែបវិនិច្ឆ័យ និងចេញសេចក្តីសម្រេចដំបូង សេចក្តីសម្រេចស្ថាពរ និងដីកានានាជូន **DCS**។ |
| **Office of Child Support Enforcement (Federal agency)** *n.* | OCSE | ការិយាល័យអនុវត្តប្រាក់អាហារូបត្ថម្ភ (ទីភ្នាក់ងារសហព័ន្ធ) | A U.S. Department of Health and Human Services (DHHS) division that monitors state IV-D agencies. **Cambodian –** ផ្នែកមួយនៃក្រសួងសេវាសុខាភិបាល និងសេវាមនុស្សនៃសហរដ្ឋអាមេរិក **(DHHS)** ដែលពិនិត្យតាមដាន **IV-D** របស់រដ្ឋ។ |
| **Order to Withhold and Deliver** *n.* | OWD | ដីកាកាត់ទុក និងបញ្ជូន | The legal notice instructing an employer, bank or other entity to take money for child support from an employee's account or asset. **Cambodian –** សេចក្តីជូនដំណឹងតាមផ្លូវច្បាប់ដែលណែនាំឲនិយោជក ធនាគារ ឬអង្គភាពផ្សេងទៀតយកប្រាក់ពីគណនី ឬទ្រព្យសកម្មរបស់និយោជិតសម្រាប់ប្រាក់អាហារូបត្ថម្ភ។ |

# English-language Learner Glossary

## English / Cambodian

| English | Abbreviation | Cambodian | English / Cambodian Definition |
|---|---|---|---|
| **Order to Withhold Income** *n.* | OWI | ដីកាកាត់ទុកប្រាក់ចំណូល | The legal notice instructing an employer to take money for child support from an employee's pay check or earnings. **Cambodian –** សេចក្តីជូនដំណឹងតាមផ្លូវច្បាប់ដែលណែនាំឲនិយោជកយកប្រាក់ពីមូលប្បទានបត្រ ទូទាត់ប្រាក់ ឬប្រាក់ចំណូលរបស់និយោជិតសម្រាប់ប្រាក់អាហារូបត្ថម្ភ។ |
| **Overpayment** *n.* | OP | ចំណាយហួសប្រមាណ | The result of paying or being paid too much. **Cambodian –** លទ្ធផលនៃការទូទាត់ប្រាក់ ឬទទួលបានការទូទាត់ប្រាក់ច្រើនពេក។ |
| **Parent** *n.* | | ឪពុក/ម្តាយ | A person who establishes a parent-child relationship by birth, adoption, voluntary acknowledgement of paternity. **Cambodian –** មនុស្សម្នាក់ដែលបង្កើតទំនាក់ទំនងរវាងឪពុក/ម្តាយ-កូនដោយកំណើត, ការទទួលចិញ្ចឹម ការទទួលស្គាល់បិតុភាពដោយស្ម័គ្រចិត្ត។ |
